00809826

E163/4/1.1.2
12/75 – 1/76



# ទង់បដិវត្ត

លេខពិសេស ធ្នូ-មករា ១៩៧៥-៧៦

00809827

E169/4/1.1.2

# ទង់បដិវត្ត

ទស្សនាវដ្ដី នៃក្រុមបក្ស

ផ្សាយចេញរាល់ខែ

## លេខពិសេស ធ្នូ-មករា ១៩៧៥-៧៦


* ឆ្នាំ១៩៦០ : មហាសន្និបាតបក្ស លើកទី I កំណត់នូវ មាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្ត ប្រជាជាតិ-ប្រជាធិបតេយ្យ

  ឆ្នាំ ១៩៧៥ : សំរេចមហាជ័យជំនះ មហាអស្ចារ្យ នៃបដិវត្ត ប្រជាជាតិ-ប្រជាធិបតេយ្យ

  ឆ្នាំ១៩៧៦ : បន្តធ្វើបដិវត្តសង្គមនិយម និងកសាងសង្គមនិយម ................ ១

* ពាក្យស្លោក សំរាប់វាយសំរុក ខ្លាំងក្លាបំផុត និងដាច់ជានិច្ច ដោយមហាលោតផ្លោះ មហាអស្ចារ្យ .... ៦៣

00809828

ឆ្នាំ១៩៦០

មហាសន្និបាតបក្សលើកទី I

កំណត់នូវមាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្ត

ប្រជាជាតិ-ប្រជាធិបតេយ្យ

ឆ្នាំ១៩៧៥

សំរេចមហាជ័យជំនះ មហាអស្ចារ្យ នៃបដិវត្ត

ប្រជាជាតិ-ប្រជាធិបតេយ្យ

ឆ្នាំ១៩៧៦

បន្តធ្វើបដិវត្តសង្គមនិយម និង

កសាងសង្គមនិយម

~☭~

ដាច់ឆ្នាំ១៩៧៥ ។ ចលនាបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ នៃប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំ ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ នៃបក្សកុម្មុយនីស្តកម្ពុជារបស់យើង បានទទួលមហាជ័យជំនះមហាអស្ចារ្យ នៅថ្ងៃ១៧មេសា១៩៧៥ ។ មាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ដែលមហាសន្និបាតបក្សលើកទី I នៃបក្សកុម្មុយនីស្តកម្ពុជាយើង បានកំណត់កាលពីឆ្នាំ១៩៦០ បានបញ្ចប់ដោយមហាជោគជ័យទាំងស្រុង និងជាស្ថាពរ ក្នុងរយៈកាលតែ១៥ឆ្នាំប៉ុណ្ណោះ ។ national democratic rev complete 12/75

ចូលឆ្នាំ១៩៧៦ ។ ឆ្នាំថ្មីចូលដំណាក់កាលបដិវត្តថ្មី ។ ចាប់ពីឆ្នាំ១៩៧៦ទៅ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ នៃបក្សកុម្មុយនីស្តកម្ពុជា យើងត្រូវធ្វើប្រយុទ្ធវាយសំរុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយមហាលោតផ្លោះ មហាអស្ចារ្យ ក្នុងការបំពេញភារកិច្ច បន្តបដិវត្តសង្គមនិយម និងកសាងសង្គមនិយម នៅកម្ពុជាប្រជាធិបតេយ្យ ជាទីស្នេហារបស់យើង ។

1/76 socialist revolution begins in DK

ថ្ងៃនេះ លើកគ្រវីទង់យុទ្ធសាស្ត្រ ប្រយុទ្ធវាយសំរុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយមហាលោតផ្លោះ មហាអស្ចារ្យ តាមពន្លឺដ៏ត្រចះត្រចង់ នៃមាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្តសង្គមនិយម និងកសាងសង្គមនិយមរបស់បក្សយើង យើងរំលឹកចលនា



បដិវត្តយើង នាកាល១៥ឆ្នាំកន្លងមក រំលឹកដល់ទង់យុទ្ធសាស្ត្រ ប្រយុទ្ធវាយសំរុកខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយមហាលោតផ្លោះ មហាអស្ចារ្យ តាមពន្លឺមាគ៌ាដ៏ត្រចះត្រចង់ ជាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ របស់បក្សយើង ។

យើងរំលឹកចលនាបដិវត្តយើង ដើម្បីអ្វី? យើងរំលឹកចលនាបដិវត្តយើង ដើម្បីរៀនសូត្រ កសាងពង្រឹង ពង្រីកគោលជំហរបដិវត្ត នៃវណ្ណៈអធនរបស់បក្សយើង ឲ្យខ្លាំងក្លាថែមទៀត នៅក្នុងបក្សទាំងមូល កងទ័ពបដិវត្តទាំងមូល ជួរបដិវត្តទាំងមូល និងក្នុងប្រជាជនយើងទាំងមូល ក្នុងប្រវត្តិសាស្ត្រនៃដំណាក់កាលថ្មី នៃបដិវត្តយើង ដើម្បីបន្តបដិវត្តសង្គមនិយម និងកសាងសង្គមនិយម ឲ្យបានទទួលមហាជោគជ័យ មហាលោតផ្លោះ មហាអស្ចារ្យ ។

## ឆ្នាំ១៩៦០

មុនឆ្នាំ ១៩៦០ បក្សយើង នៅមិនទាន់មានមាគ៌ាជាយុទ្ធសាស្ត្រ ជាយុទ្ធវិធីនៅឡើយ ។ យើងមានតែការកិច្ចចំពោះមុខ គឺប្រឆាំងចក្រពត្តិ ពិសេសចក្រពត្តិអាមេរិក និងបរិវារ ។ គ្មានមាគ៌ាបដិវត្តជាយុទ្ធសាស្ត្រ និងយុទ្ធវិធី ប្រៀបដូចជាដើរក្នុងរូងភ្នំងងឹតឈឹង ។

NB: no mention of anything before 1960 ?

national democratic revolution: attack US imperialism, its lackeys, feudalists, reactionary capitalists

ឆ្នាំ១៩៦០ បក្សបើកមហាសន្និបាតបក្សលើកទី I ។ មហាសន្និបាតបក្សលើកទីI បានសំរេចជាឯកច្ឆន្ទកំណត់មាគ៌ាជាយុទ្ធសាស្ត្ររបស់បដិវត្តកម្ពុជា ជាបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ គឺវាយចក្រពត្តិ ពិសេស ចក្រពត្តិអាមេរិក និងបរិវារ វាយសក្តិភូមិ និងនាយទុនប្រតិកិរិយា ។ កម្លាំងបដិវត្ត គឺកម្លាំងប្រជាជាតិទាំងមូល ដោយផ្អែកលើសម្ពន្ធភាពកម្មករ-កសិករ។ រូបភាពតស៊ូបដិវត្ត គឺហិង្សាបដិវត្តខាងនយោបាយ និងហិង្សាបដិវត្តខាងអាវុធ ។ បក្សកុម្មុយនីសកម្ពុជាតែ១គត់ ជាបក្សដឹកនាំបដិវត្តកម្ពុជា ។ ទិសឈានឡើងរបស់បដិវត្តគឺ សំរេចបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ហើយឈានទៅធ្វើបដិវត្តសង្គមនិយម និងកសាងសង្គមនិយម និងកុម្មុយនីសនិយម នៅកម្ពុជា ។

នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ធំសំខាន់ណាស់ ចំពោះបក្ស បដិវត្ត ចំពោះប្រជាជន និងប្រជាជាតិកម្ពុជាយើង ។ ជាពន្លឺយ៉ាងត្រចះត្រចង់ នាំផ្លូវពលនាបដិវត្តកម្ពុជា ដើម្បីឈានទៅរំដោះជាតិ រំដោះប្រជាជន រំដោះវណ្ណៈ ។ លើកមាគ៌ាបដិវត្តជាយុទ្ធសាស្ត្របានត្រឹមត្រូវ គឺបំផុសបានជំនឿបដិវត្ត យ៉ាងខ្លាំងក្លា ដំបូងបង្អស់ គឺជំនឿក្នុងជួរគម្មាភិបាលបក្ស ។ មានជំនឿ គឺខ្លាំង មានកម្លាំងប្រយុទ្ធយ៉ាងមោះមុត ។



## ឆ្នាំ១៩៦១

បក្សបើកវគ្គ ប្រយុទ្ធវាយសំរុកអប់រំ ឲ្យគម្មាភិបាលបក្សទាំងនៅជនបទនិងទីក្រុង បានជ្រួតជ្រាប និងក្តាប់មាគ៌ាជាយុទ្ធសាស្ត្របដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ បានមួយកំរិតសំខាន់ ។ តាមពន្លឺនៃមាគ៌ាជាយុទ្ធសាស្ត្រនេះ សតិអារម្មណ៍គម្មាភិបាល បានរីកឡើង ។ គោលជំហរបដិវត្ត រឹងជាងមុន ។ ស្គាល់មិត្ត ស្គាល់សត្រូវ ច្បាស់ជាងមុន ។ មានមាគ៌ាបដិវត្តត្រឹមត្រូវ សតិអារម្មណ៍បដិវត្តជ្រះស្រឡះ ការចាត់តាំងរបស់បក្ស ក៏មានរបៀប តាមលក្ខការណ៍ចាត់តាំងរបស់បក្ស ។ ចលនាតស៊ូរបស់មហាជន នៅជនបទនិងទីក្រុង មានការដឹកនាំ កាន់តែត្រឹមត្រូវ តាមមាគ៌ារបស់បក្ស ហើយផុលផុសកាន់តែខ្លាំងជាងមុន ក្រោមពាក្យស្លោកប្រឆាំងចក្រពត្តិអាមេរិក និងទាមទារតែប្រដ៏វភាព ទាមទារសិទ្ធិសេរីភាព ប្រជាធិបតេយ្យ ។ បានទទួលពន្លឺនៃមាគ៌ាបដិវត្តជាយុទ្ធសាស្ត្រ គុណភាពគម្មាភិបាល ខាងគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំង ចំរើនឡើងមួយកំរិត ។ ចលនាតស៊ូរបស់មហាជន នៅជនបទនិងទីក្រុង កាន់តែមានគុណភាពបដិវត្ត ។

## ឆ្នាំ១៩៦២

ចក្រពត្តិអាមេរិក បរិវារ និងវណ្ណៈសក្តិភូមិ-នាយទុន ប្រតិកិរិយាកាន់អំណាច បានបង្កើនសកម្មភាពវាយប្រហារបក្ស វាយប្រហារចលនាតស៊ូ របស់ប្រជាជន-មហាជន នៅជនបទនិងទីក្រុងកាន់តែខ្លាំងក្លា ឃោរឃៅជាងមុន ៗ

ក្តាប់ជាប់នូវមាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស កម្មាភិបាល នៅជនបទនិងទីក្រុង បានបំផុសចលនាមហាជនតស៊ូថែមទៀត ៗ យើងការពារបានកម្លាំងបក្ស ការពារបានកម្លាំងមហាជន រក្សា និងបំផុសបាន ចលនាតស៊ូប្រជាជាតិ-ប្រជាធិបតេយ្យ កាន់តែខ្លាំង ធំទូលាយ និងជ្រៅជាងមុន ៗ ចលនាតស៊ូប្រជាជាតិ-ប្រជាធិបតេយ្យរបស់មហាជន នៅជនបទនិងទីក្រុង ក្រោមការដឹកនាំរបស់បក្ស ឋិតក្នុងឋានៈវាយសំរុកជាប់ ៗ ទំនាស់រវាងចក្រពត្តិ ពិសេសចក្រពត្តិអាមេរិក និងប្រជាជាតិ-ប្រជាជន កាន់តែឡើងស្រួច ៗ ទំនាស់រវាងសក្តិភូមិ-ម្ចាស់ដី និងកសិករ ចេះតែឡើង ៗ ទំនាស់រវាងកម្មករ-ពលករ និងនាយទុន ចេះតែឡើង ៗ ភ្លើងបដិវត្ត កាន់តែឆេះខ្លាំងឡើង ៗ កម្លាំងបក្ស កម្លាំងបដិវត្ត កាន់តែបានពង្រឹង និងពង្រីកជាលំដាប់ ៗ



## ឆ្នាំ១៩៦៣

គឺនៅក្នុងសភាពទំនាស់ ដ៏តឹងតែង រវាងខ្មាំងនិងបដិវត្ត និងក្នុងសភាពដែលភ្លើងបដិវត្ត កាន់តែឆេះខ្លាំងនេះ បក្សបាន បើកមហាសន្និបាតបក្សលើកទី II នៅដើមឆ្នាំ ១៩៦៣ ដើម្បី បញ្ជាក់ច្បាស់ថែមទៀត នូវមាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ ប្រជាធិបតេយ្យ ហើយជំរុញអនុវត្តមាគ៌ានេះ ឲ្យខ្លាំងក្លាថែមទៀត ៗ ខ្លឹមសារនៃមហាសន្និបាតបក្សលើកទីII ចេញពីចលនា ប្រយុទ្ធជាក់ស្តែង ក្នុងរយៈជិត ៤ ឆ្នាំ ៗ

ពិសោធន៍នៃការដឹកនាំចលនា ជិត៤ឆ្នាំមកនេះ បាន ពង្រឹងទស្សនៈ គោលជំហរ នយោបាយ សតិអារម្មណ៍ ចាត់តាំង ក្នុងផ្ទៃក្នុងបក្ស បានមួយកំរិតខ្ពស់ជាងមុន ៗ ជាពិសេស មហាសន្និបាតបក្សលើកទី II បានចងក្រងនូវសាមគ្គីភាព-ឯកភាពផ្ទៃក្នុងបក្ស ទាំងខាងទស្សនៈ គោលជំហរ សតិអារម្មណ៍ និងចាត់តាំង បានរឹងប៉ឹង គក់ក្តៅ ជំនឿទុកចិត្តលើអនាគតនៃបដិវត្តខ្លួន ៗ ពិសេសទៀត . គោលជំហរឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង បានជ្រួតជ្រាប

2nd cons = internal unity (= PPas sec)

= independence, self-reliance, mastery, mastery of one's own fate

00809832



ថែមទៀត ជាសាច់ជាឈាម អាស្រ័យដោយចលនាបដិវត្តជាក់ស្ដែង បញ្ជាក់ជារូបិយ ។ តើចលនាជាក់ស្ដែង បញ្ជាក់អ្វី? ចលនាជាក់ស្ដែង បានបញ្ជាក់ច្បាស់ថា មាគ៌ាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ - ប្រជាធិបតេយ្យ ផ្អែកលើសម្ពន្ធភាពកម្មករ - កសិករ ក្រោមការដឹកនាំផ្ដាច់មុខតែ១គត់ របស់បក្សកុម្មុយនីសកម្ពុជា គឺត្រឹមត្រូវជាទីបំផុត ។

ដើម្បីម្ចាស់ការ ដឹកនាំចលនាបដិវត្តប្រជាជាតិ - ប្រជាធិបតេយ្យ វាយសំរុកទៅលើខ្មាំងកាន់តែខ្លាំងក្លា តាមសេចក្ដីសំរេចចិត្ត របស់មហាសន្និបាតបក្សលើកទី II ក្បាលម៉ាស៊ីនដឹកនាំបក្ស បានត្រូវចុះទៅរៀបចំចាត់តាំង និងពង្រឹងនៅមូលដ្ឋានបន្អែកជនបទ ។ កម្មាភិបាលមួយចំនួនសំខាន់ ត្រូវចុះផ្សាប់ជនបទ ។ នេះជាជំហានមួយសំខាន់ នៃការពង្រឹងការដឹកនាំរបស់បក្ស ទូទាំងប្រទេស ។ ដោយហេតុនេះ ការដឹកនាំរបស់បក្ស កាន់តែមានលក្ខណៈរឹងប៉ឹង ឯកភាពគ្នាខាងទស្សនៈ គោលជំហរ សតិអារម្មណ៍ ហើយជិតស្និទ្ធនឹងចលនាកសិករ ដែលជាកម្លាំងធំសំខាន់ របស់ចលនាបដិវត្តប្រជាជាតិ - ប្រជាធិបតេយ្យ ។

ចក្រពត្តិអាមេរិក និងបរិវារ ដែលមានអាក្សត់លន់ណុល សិរិមតៈ-សឺងង៉ុកថាញ់ជាមេ មានផែនការធ្វើរដ្ឋប្រហាររំលំប្រទេស



កម្ពុជា អព្យាក្រិត និងវាយកំទេចកម្លាំងបក្ស កម្លាំងប្រជាជន-មហាជន ។ ដោយមានស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ និងវៃឈ្លាសបក្សបានចាក់យកឱកាសនេះ បំផុសចលនាប្រជាជន - មហាជនទាំងជនបទ ទីក្រុង ប្រឆាំងយ៉ាងខ្លាំងក្លា ផែនការធ្វើរដ្ឋប្រហាររបស់ចក្រពត្តិអាមេរិក និងពួកអាក្សត់បរិវារ ។ ដោយរួមរំព្រាក្យស្លោក ប្រឆាំងរដ្ឋប្រហារនិងពួកអាក្សត់ ការពារប្រទេស ការពារសន្តិភាព អព្យាក្រិត ជាមួយនឹងពាក្យស្លោក តស៊ូ ទាមទារដីធ្លីរបស់កសិករ ទាមទារតម្លើងប្រាក់ខែរបស់កម្មករ ទាមទារសិទ្ធិសេរីភាពរបស់សិស្ស និស្សិត បញ្ញាជនទៅទីក្រុង ចលនាបាតុកម្មមីទីញ ចលនាតស៊ូចំហ ស្របច្បាប់ មិនស្របច្បាប់ តស៊ូសំងាត់កំចាត់ពួកក្សត់នៅតាមជនបទ បានផ្ទុលផ្ទុសបន្តកន្ទុយគ្នា ពីជនបទមួយទៅជនបទមួយ ពីទីក្រុងមួយទៅទីក្រុងមួយទៀត ធ្វើឲ្យពួកខ្មាំងវិលក្បាល តក់ស្លុត ភិតភ័យ បាត់ម្ចាស់ការ ធ្វើឲ្យផែនការរដ្ឋប្រហាររបស់ខ្មាំង ត្រូវបរាជ័យ ។

ដោយមានមាគ៌ាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ត្រឹមត្រូវ ច្បាស់លាស់ ហើយបានពង្រឹងក្នុងមហាសន្និបាតបក្សលើកទីIIថែមទៀត ហើយដោយមាគ៌ានេះ បានចូលជ្រៅទៅក្នុងកម្មាភិបាល - បក្ខជន ប្រជាជន - មហាជន ដូច្នោះចលនា

00809833



គស៊ីដោយហឹង្សាបដិវត្ត ដោយយកហឹង្សាបដិវត្តខាងនយោបាយជាសំខាន់ ហើយយកហឹង្សាបដិវត្តខាងអាវុធរួមផ្សំជាបន្ទាប់ ចលនាតស៊ូរបស់ប្រជាជន-មហាជន នៅជនបទនិងទីក្រុង កាន់តែផុលផុសមានច្រើនទម្រង់ ច្រើនរូបភាព ៗ

ទន្ទឹមនឹងនេះ គណៈយោធាសំងាត់របស់បក្ស ដែលបានរៀបចំកាំងពីឆ្នាំ១៩៦០ ដោយជ្រើសរើសយកក្នុងយុវជនកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម ដើម្បីធ្វើជាកងការពារសំងាត់ បានចាប់ផ្តើមធ្វើសកម្មភាព ដូចជាឃាមល្បាត ការពារកម្មាភិបាល ជូនដំណើរកម្មាភិបាល កំទេចគិញ្ចា ចារបុរសឃោរឃៅ ដែលរាំមកបង្ក្រាញមូលដ្ឋាន ភគក្បាតប្រជាជន ចាប់ចងកម្មាភិបាល ៗលៗ ឯប្រជាជន-មហាជន កំកាន់តែឃើញថា បើតស៊ូនយោបាយទទេមានតែត្រូវខ្មាំងបង្ក្រាប ទាល់តែបំពាក់អាវុធដែរ ទើបតស៊ូបាន ៗ ដូច្នោះ ប្រជាជន-មហាជន ដែលត្រូវជិះជាន់សង្កត់សង្កិន មានទស្សនៈតស៊ូដោយហឹង្សាអាវុធ ហើយត្រៀមអាវុធ ជាកាំបិត-ពូថៅ ដំបង-ធ្នូ-ស្នា ដើម្បីការពារភូមិ-ឃុំ ការពារប្រជាជន ការពារកម្មាភិបាលរបស់បក្ស ៗ



## ឆ្នាំ១៩៦៤-១៩៦៥-១៩៦៦

ក្នុងរយៈពេល ៣ ឆ្នាំនេះ ចលនាតស៊ូប្រឆាំងចក្រពត្តិអាមេរិក បរិវារ និងចលនាតស៊ូពីបញ្ហាដីធ្លីនៅជនបទ បញ្ហាតស៊ូកែប្រែជីវភាព ប្រជាជនប្រចាំថ្ងៃ តស៊ូទាមទារសិទ្ធិសេរីភាពប្រជាធិបតេយ្យ បានផុលផុសស្ទើរតែពាល់ទី១ ៗ ចលនាប្រជាជនមហាជន ប្រឆាំងចក្រពត្តិអាមេរិក ឡើងខ្ពស់ជាងពេលណា១តាំងពីមុន ៗ ឆ្នាំ១៩៦៤ ប្រជាជន យុវជនសិស្ស នៅទីក្រុងភ្នំពេញរាប់ម៉ឺន១នាក់ ធ្វើបាតុកម្មវាយស្ថានទូតចក្រពត្តិអាមេរិក និងវាយមន្ទីរវប្បធម៌ របស់ចក្រពត្តិអាមេរិក រហូតដល់ដេញទូតចក្រពត្តិអាមេរិក ចេញពីប្រទេសកម្ពុជា ហើយបដិសេធជំនួយមានពិសពុលរបស់ចក្រពត្តិអាមេរិកទាំងអស់ ទាំងជំនួយយោធា-សេដ្ឋកិច្ចវប្បធម៌-សង្គមកិច្ច ៗ

ឯនៅជនបទវិញ ចលនាកសិករ តស៊ូប្រឆាំងសក្តិភូមិម្ចាស់ដី ប្រឆាំងវណ្ណៈកាន់អំណាច ជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ ប៉ូលីស ទាហាន គិញ្ចា តាមទារដីធ្លី ប្រឆាំងពន្ធដារ ក្រវ៉ាត់ការ កំណែនគេណ្ឌកៀរ ក៏កាន់តែផុលផុស ៗ ល ៗ

កម្មាភិបាលដឹកនាំ កាន់តែចុះជនបទ ចុះជាប់ចលនាកសិករ ចុះជាប់ចលនាកម្មករ យុវជនសិស្ស ជំរុញចលនាជាប់ផុតក្បើងបដិវត្ត ក្បើងកំហឹងប្រជាជាតិ កំហឹងវណ្ណៈគេះជាប់ជានិច្ច ។

ក្នុងចលនាក្តៅ ១៩៦៤-១៩៦៥-១៩៦៦នេះ បក្សបានកសាងផ្លូវកម្មាភិបាលលះបង់ បានកាន់តែច្រើន កសាងអង្គការសំងាត់ កាន់តែច្រើន ។ គោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស កាន់តែបានរឹងប៉ឹង ឯកភាពគ្នា ។ គោលជំហរឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង កាន់តែបានពង្រឹងជាក់ស្តែង ក្នុងចលនាបដិវត្ត ។

## ឆ្នាំ១៩៦៧

សភាពការណ៍តស៊ូបដិវត្ត កាន់តែខ្លាំងក្លា ។ ការតស៊ូដោយហិង្សាការពារ បានផ្ទុះក្លាមនៅជនបទ លេចធ្លោជាងគេ គឺ «ព្រឹត្តិការណ៍សំឡូត» ។ នៅទីក្រុង ចលនាបាតុកម្ម មិទិញ គាំទ្រចលនាតស៊ូរបស់ប្រជាជននៅជនបទ ប្រឆាំងពួកក្បត់លន់-ណុល និងដៃជើងវា បានស៊ីសង្វាក់គ្នាជាក្តុងមួយ ធ្វើយតូងពីទីក្រុងទៅជនបទ ពីជនបទទៅទីក្រុង ទូទាំងប្រទេស ។ ប្រជាជន



ជាពិសេស កសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម យល់ឃើញដោយខ្លួនគេច្បាស់ណាស់ថា តស៊ូនយោបាយទទេ មានតែត្រូវខ្ទាំងបង្ក្រាប កាត់ក្បាល ចាប់ចង ដាក់គុកច្រវាក់ ទាល់តែបំពាក់កាំភ្លើងដៃ បានតស៊ូបាន តាំងប្រជាជាតិ តាំងប្រជាធិបតេយ្យ ។

ដូច្នេះ សភាពការណ៍ឆ្នាំ១៩៦៧ ពង្រាងនយោបាយខាងចលនាតស៊ូបដិវត្ត របស់ប្រជាជន-មហាជន ខាងបំពាក់ហិង្សានយោបាយនិងអាវុធ ។

សរុបពិសោធន៍ មួយចំនួនសំខាន់ នៃចលនាបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ពីឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦៧ ឃើញថា:

Lessons of 60-67

### ១. មាគ៌ារបស់បក្ស

បក្សយើងកំណត់មាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្តប្រជា-ជាតិ-ប្រជាធិបតេយ្យ បានត្រឹមត្រូវ ហើយម្ចាស់ការក្នុងការដឹកនាំអនុវត្ត ក្នុងរយៈកាលនីមួយៗបានជាក់ស្តែង ទៅតាមសភាពការណ៍ក្នុងជាន:រាយសំរុកជាប់ជានិច្ច ។

យើងរួមផ្សំការតស៊ូប្រជាជាតិ និងតស៊ូប្រជាធិបតេយ្យបានល្អ តាំងខាងយុទ្ធសាស្ត្រ យុទ្ធវិធី តាំងពាក្យស្លោកតស៊ូប្រចាំថ្ងៃ ។ ដូច្នេះ ប្រមូលកម្លាំងប្រជាជន-មហាជន បានបំផុស

00809835



ចលនាតស៊ូបាន ទាំងប្រជាជាតិ-ប្រជាធិបតេយ្យ ហើយកម្លាំងនេះធំទូលាយ តែផ្អែកទីងប៉ុង លើកម្លាំងសម្ព័ន្ធភាពកម្មករ-កសិករ ក្រោមការដឹកនាំរបស់បក្ស ។

## ២. សតិអារម្មណ៍របស់បក្ស

ចលនាទាំងក្លា សតិអារម្មណ៍ក៏រីកចំរើន ។ ស្មារតីស្នេហាជាតិបដិវត្ត ផុលផុស ពុះកញ្ជ្រោលជាប់ជានិច្ច ។ សតិអារម្មណ៍វណ្ណៈ តស៊ូវណ្ណៈ បានពង្រឹងនិងពង្រីកថែម ។ ឃើញទំនាស់វណ្ណៈកាន់តែច្បាស់ កាល់ៗ កាល់ផ្ទាំ ។ ឃើញការប្រយុទ្ធវណ្ណៈច្បាស់ គឺងតែង ស្លាប់-រស់ ទាំងក្នុងជួរបក្ស ទាំងក្នុងជួរប្រជាជន-មហាជន ។ ដូច្នោះ គោលជំហរសតិអារម្មណ៍វណ្ណៈ និងតស៊ូវណ្ណៈ បានត្រូវសំរួចឲ្យឡើងក្ដៅគគុក ឆាបឆេះជានិច្ច ទាំងក្នុងបក្ស ទាំងក្នុងប្រជាជន-មហាជន ដែលប្រយុទ្ធវាយសំរុកជាប់ ហើយតាមការប្រយុទ្ធតទៅទៀត កាន់តែខ្លាំងក្លា ។

class struggle within the Party

បក្សយើងជឿជាក់យ៉ាងច្បាស់លាស់ថា សតិអារម្មណ៍បដិវត្ត របស់កម្មាភិបាល-បក្ខជន ប្រជាជន-មហាជន ពុះពារយ៉ាងនេះ ធ្វើឲ្យយើងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីប្រយុទ្ធនឹងខ្មាំងខ្លាំងក្លា ក្ដៅគគុកបានជាជាចខាត ។



## ៣. ចាត់តាំងរបស់បក្ស

មាគ៌ាច្បាស់លាស់ បានសាកល្បងដកពិសោធន៍ខុសត្រូវ ក្នុងចលនា ។ សតិអារម្មណ៍ច្បាស់លាស់ បានសាកល្បងផុតដំសាពុះសាឡើង ក្នុងចលនាក្ដៅជាប់ជានិច្ច ។ ចាត់តាំង ក៏បានសាកល្បងពង្រឹងពង្រីកក្នុងចលនា ។ ការប្រយុទ្ធ នាំឲ្យបក្ខជន-កម្មាភិបាល យល់ច្បាស់ ជ្រួតជ្រាបនូវមាគ៌ា ក្ដាប់មាគ៌ាជាប់ ឃើញខុស ឃើញត្រូវ ដោយច្បាស់លាស់ខ្លួនឯង ។ ដោយបានផុតដំសតិអារម្មណ៍ ក្នុងចលនាតស៊ូក្ដៅជាប់ បក្សកំចាត់សំអាតពួកស្មាក់ស្មើរ ពួកសារភាពខ្មាំងបានមួយចំនួន ។ ទន្ទឹមនឹងនេះ បានពង្រឹងនិងពង្រីកជួរកម្មាភិបាលចាស់-ថ្មីបានច្រើន ។ កម្មាភិបាលថ្មីនិងចាស់ កសាងក្នុងចលនា មានទំនាស់ជាមួយខ្មាំងជាប់ជានិច្ច ។ សមមិត្តទាំងនេះ ត្រូវប្រយុទ្ធដោយហ៊ានផ្សាជាមួយខ្មាំង ។ កម្មាភិបាលមួយចំនួនច្រើន ចុះទៅជនបទ បំផុសបំផុលកសិករ រៀបចំចាត់តាំងកសិករ ឲ្យបានខ្លាំងក្លាគ្រប់ទីកន្លែង ពិសេសតាមជនបទចុងកាត់មាត់ញក ហើយក្នុងចលនានេះ ពង្រឹង ពង្រីកជួរកម្មាភិបាល-បក្ខជន នៅជនបទថែមទៀត ។

purge of capitulationists goes hand in hand with cadre-building

កម្មាភិបាល-បក្ខជនល្អ ត្រូវជាប់ចលនា ប្រយុទ្ធក្នុង

ចលនា កសាងគោលជំហរ នយោបាយ សតិអារម្មណ៍ ចាត់តាំងក្នុងចលនា បន្ថែមសមត្ថភាពដឹកនាំក្នុងចលនា ដោយដកពិសោធន៍ខុស-ត្រូវក្នុងចលនា ។

កម្មាភិបាល-បក្ខជនយើងទាំងអស់ ឈរលើគោលជំហរនៃចលនាបដិវត្ត របស់បក្សខ្លួនច្បាស់លាស់ ឈរលើគោលជំហរឯករាជ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ជឿជាក់លើប្រជាជនខ្លួន លើចលនាខ្លួន លើការដឹកនាំរបស់បក្សខ្លួន ។ ឃើញចលនាតស៊ូត្រឹមត្រូវ ។ បើមិនប្រយុទ្ធ មិនតស៊ូនឹងចក្រពត្តិ សក្តិភូមិ និងនាយទុនប្រតិកិរិយាទេ គឺមុខជាពុកពួយបដិវត្តឡើងខ្ទេចខ្ទី ។ ហើយយើងមិនពុកពួយយើងជាប់ ក៏មិនទុកឲ្យយើងនៅសុខទេ ។

ជាពិសេសទៀត ក្នុងចលនាតាំងពីឆ្នាំ ១៩៦០ ដល់ ១៩៦៧ អាស្រ័យតាមពន្លឺនៃមហាសន្និបាតបក្សទាំងពីរលើក និងអាស្រ័យតាមការពិសោធន៍ នៃចលនាជាក់ស្តែង នៅក្នុងប្រទេសរបស់ខ្លួន បក្សយើងបានពង្រឹងគោលជំហរឯករាជ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង បានថែមមួយកំរិតទៀត លើសពេលមុនៗ ។ យើងមានជំនឿច្បាស់ណាស់ថា ប្រជាជនយើងខ្លាំងក្លា ។ បក្សយើង មានសមត្ថភាពដឹកនាំប្រជាជន ទាំងជនបទ ទាំងទីក្រុង ។ យើងជឿជាក់ ហើយ

more independence mastery self-reliance



បងប្អូនកសិករសហករណ៍ នៅភូមិភាគឧត្តរ កំពុងប្រយុទ្ធលើកភ្លឺទឹកប្រឡាយថ្មី កាត់ខ្វែងផ្ទៃស្រែជាក្រឡាឈើត្រង់ឡើងបានទូទៅ និងម្ចាស់ការជាស្រេច នៅរដូវប្រាំងនេះ ។

North Zone irrigation works

00809836

យើញច្បាស់ថា ប្រជាជនយើងតស៊ូ ដោយហឹង្សានយោបាយក៏បាន ដោយហឹង្សាអាវុធក៏បាន ហើយជឿជាក់ថាវាយសំរុកខ្មាំងគឺឈ្នះ វាយសំរុកជាបន្តបន្ទាប់បាន យកជ័យជំនះជាបន្តបន្ទាប់បាន។

## ឆ្នាំ១៩៦៨-១៩៧០

### ១. ការបំផុសចលនាតស៊ូបដិវត្ត តាមមាគ៌ារបស់បក្ស

បក្សបានកំណត់ថា ត្រូវតស៊ូនយោបាយផង អាវុធផង តាំងពីឆ្នាំ១៩៦៨នេះទៅ ។ ដូច្នោះ ខែ១ឆ្នាំ១៩៦៨ យើងផ្ទុះអាវុធ នៅភូមិភាគពាយ័ព្យ(បាត់ដំបង) ។ ខែ២ឆ្នាំ១៩៦៨ នៅភូមិភាគនិរតី ។ ខែ៣ឆ្នាំ១៩៦៨ នៅភូមិភាគបូព៌ា ។ ចុងខែ៣ នៅភូមិភាគឥសាន ហើយក្នុងខែ៣និងខែ៤ឆ្នាំដដែល នៅភូមិភាគឧត្តរ ។

ហេតុនេះ នៅដើមឆ្នាំ១៩៦៨ មានការផ្ទុះអាវុធទូទៅ ។ គឺក្នុង១៩ខេត្ត យើងផ្ទុះអាវុធ១៧ខេត្ត ។

ក្នុងការតស៊ូនយោបាយផង អាវុធផងនេះ សភាព-ការណ៍សត្យានុមតិទៅលើសកលលោក មិនអំណោយឲ្យយើងទេ ។ តែបក្សយើង ជឿជាក់លើមាគ៌ារបស់ខ្លួន លើចលនារបស់ខ្លួន

VNse-Chinese objec-tions

ហើយឃើញច្បាស់ នូវលទ្ធភាពពង្រឹងនិងពង្រីកចលនានេះបាន ។ ត្រង់នេះ នាំឲ្យផ្ទៃក្នុងបក្សយើងពង្រឹងគោលជំហរ ជាមេរៀនជាបន្តបន្ទាប់ គឺជាកត្តាអត្តនោម័តិ ជាកត្តាសំរេចជាមូលដ្ឋាន ត្រូវឈរលើគោលជំហរខ្លួនឧបត្ថម្ភខ្លួន ខ្លួនកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។ ន័យសំខាន់នៃខ្លួនឧបត្ថម្ភខ្លួន គឺផ្អែកលើកម្លាំងប្រជាជនឯងជាសំខាន់ ដូច្នោះ យើងបំផុសប្រជាជន នៅឆ្នាំ១៩៦៨ ធ្វើកុប្បកម្ម ដណ្តើមរដ្ឋអំណាចភូមិ-ឃុំពីខ្មាំង និងដណ្តើមអាវុធពីខ្មាំង ដើម្បីធ្វើសង្គ្រាមឈ្លបតទៅទៀត ។

subjective factor decisive

ពេលនោះ កត្តាល្អជាអត្តនោម័តិរបស់យើង គឺបក្សដឹកនាំប្រជាជនជាប់ស្អិត ។ មានមាគ៌ាត្រឹមត្រូវ សតិអារម្មណ៍ត្រឹមត្រូវ ការចាត់តាំងត្រឹមត្រូវ ។ កម្មាភិបាលមជ្ឈិមបក្ស ឯកភាពគ្នាជាធ្លុងមួយគ្រប់ភូមិភាគ ។ ប្រជាជនផុលផុសខ្លាំងក្លា ដោយហឹង្សានយោបាយ និងហឹង្សាអាវុធ ។ ដូច្នោះ ពិតមែនតែសភាពការណ៍សកលលោក មិនអនុគ្រោះឲ្យយើងក្តី យើងខ្វះខាតទាំងសព្វទាំងគ្រប់ក្តី តែយើងវាយខ្មាំងបានយ៉ាងខ្លាំងក្លា ធ្វើឲ្យពួកវាត្រូវរត់ខ្ចាត់ខ្ចាយ ។

need total agreement in CC and all Zones

## ២. សតិអារម្មណ៍របស់បក្ស

សតិអារម្មណ៍ផ្ទៃក្នុងបក្ស ផ្ទៃក្នុងកងទ័ព ផ្ទៃក្នុងប្រជាជន



លះបង់ប្រយុទ្ធដាច់ខាត ហើយប្រយុទ្ធខ្លាំងក្លាណាស់ ។ គេកាន់តែឃើញច្បាស់ថា ខ្លួនត្រូវឧបត្ថម្ភខ្លួន ខ្លួនត្រូវកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។

យើងបន្តប្រយុទ្ធនយោបាយ នៅភ្នំពេញ និង ទីក្រុងផ្សេងៗ ។ ជនបទ ក៏បន្តតស៊ូនយោបាយនិងអាវុធ ។ យើងតស៊ូទាំងពីររូបភាព ដើម្បីរួមផ្សំវាយខ្មាំង ។ ទីក្រុង តស៊ូនយោបាយតទៅទៀត ហើយបំពាក់អាវុធសំរាប់ការពារខ្លួន ។ ឯជនបទ បំផុសចលនាកសិករ ឲ្យតស៊ូនយោបាយផង និងតស៊ូអាវុធផង ។ ទន្ទឹមនឹងនេះ បក្សបំផុសធ្វើសង្គ្រាមឈ្លបពាសពេញ ដោយប្រើអាវុធបូរាណ រួមផ្សំនិងអាវុធសម័យ ។ ពេលនោះវណ្ណៈកាន់អំណាចវាប្រកាសថា វាយខ្មែរក្រហមឲ្យលៀនអណ្តាត ។ ពួកវាប្រមូលកម្លាំងទាំងអស់ទៅវាយយើង ។ មេទ័ពទាំងអស់របស់ខ្មាំងតាំងពីអាលន់ណុល អាជូឡុង និងពួកមេបញ្ជាការធំៗវាទាំងអស់ទៅវាយយើង ។ តែផ្ទុយទៅវិញ មិនគ្រាន់តែវាទប់ទល់យើងមិនបាន យើងថែមទាំងពង្រឹងនិងពង្រីកតំបន់រំដោះពេលនោះ បានជាបណ្តើរៗ ទៀតផង ។ ការលំបាករបស់យើង ក៏មានច្រើនដែរ ។ ប៉ុន្តែមិនសារភាពខ្លាំង ពីព្រោះការងារនយោបាយ ការងារសតិអារម្មណ៍ បានត្រូវអប់រំជាប់ ។ បក្សយើងក្តាប់ជាប់ ទាំងផ្ទៃក្នុង

A- Tioulong

upper strata cannot withstand difficulty



បក្ស តាំងផ្ទៃក្នុងប្រជាជន ។ អញ្ចឹងហើយ បានជាសតិអារម្មណ៍ រឹងប៉ឹង ប្រយុទ្ធដាច់ខាត ទ្រាំទ្រលំបាកវេទនា ។ ការពិសោធន៍ កន្លងមកឃើញថា បក្សបានលត់ដំក្នុងចលនា ក្នុងភ្លើងសង្គ្រាម បានឯកភាពគ្នាជាធ្លុងមួយ ហើយប្រយុទ្ធវាយសំរុកជាធ្លុងមួយ ។ ពិសោធន៍មួយទៀត គឺប្រជាជនមូលដ្ឋានទ្រាំទ្រលំបាកវេទនាមិន ខ្វែន ។ បើប្រជាជនស្រទាប់កណ្តាលនិងស្រទាប់លើ មិនអាច ទ្រាំទ្រដូច្នេះបានទេ ។ ការនេះ នាំឲ្យយើងរិតតែជឿជាក់លើមាគ៌ា ចាត់តាំងរបស់បក្ស ដែលផ្អែកលើមាគ៌ាវណ្ណៈរបស់បក្ស និងលើ ចលនាបដិវត្ត ។

## ៣. ចាត់តាំងរបស់បក្ស

បក្សយើង បានពង្រីកនិងពង្រឹងកម្លាំងគ្រប់ផ្នែក បាន ជាច្រើន ក្នុងរយៈកាល២ឆ្នាំប៉ុណ្ណោះ ។ មូលដ្ឋាននយោបាយ នៅ ក្នុងប្រជាជននៅជនបទបានរីកធំធាត់ ព្រមទាំងមូលដ្ឋានបង្អែក នៅជនបទទូទាំងប្រទេសក៏បានពង្រឹងនិងពង្រីកថែម ។ ឯកងទ័ព បដិវត្តក៏រីកធំធាត់ ។ កន្លែងខ្លះ ចាត់តាំងជាកងអនុសេនាធំ ហើយ នៅដើមឆ្នាំ១៩៧០ ។ កងទ័ពនេះ មានសមត្ថភាពវាយ និងទប់ទល់ខ្មាំងបាន ។ ខ្មាំងវាទៅកតញ្ញក ច្រើនកងវរសេនាតូច



ក៏កងទ័ពបដិវត្តយើង ទប់ទល់បាន ថែមទាំងវាយខ្មាំងឲ្យបាក់ដៃ ជាបន្តបន្ទាប់ទៀត ។

ដូច្នេះ រយៈកាលឆ្នាំ១៩៦៨ ដល់ដើមឆ្នាំ ១៩៧០ បក្ស បានរីកនិងរីកថែម ប្រជាជន ក៏រីកនិងរីកថែម កងទ័ព ក៏បានរីកនិងរីកថែម មូលដ្ឋានបង្អែក ក៏បានរីកនិងរីកថែម ។

សភាពការណ៍បដិវត្តយើង កំពុងរីក លូតលាស់យ៉ាង នេះ ស្រាប់តែមានផ្ទុះរដ្ឋប្រហារក្លាម នៅថ្ងៃ១៨ខែ៣ឆ្នាំ១៩៧០ ។

# ឆ្នាំ១៩៧០ដល់១៩៧៥

## ១. សភាពការណ៍ក្រោយរដ្ឋប្រហារ ថ្ងៃ១៨-៣-៧០

ខែ ៣ ឆ្នាំ ១៩៧០ ចក្រពត្តិអាមេរិក និងពួកអាក្សត់ លន់ណុល បានធ្វើរដ្ឋប្រហារ ។ ពេលវាធ្វើរដ្ឋប្រហារក្លាម សភាពការណ៍នយោបាយប្រែប្រួលភ្លាម ទាំងក្នុងប្រទេស ទាំង ក្រៅប្រទេស ។ ក្នុងប្រទេស បក្សយើងដណ្តើមបាន កម្លាំង ប្រជាជនបានច្រើនថែមទៀត រហូតដល់ពួកវណ្ណៈកាន់អំណាច ជា សក្តិភូមិ នាយទុន ដែលប្រឆាំងយើងពីកាលមុន ក៏យើងដណ្តើម បាន ពីព្រោះ មុនរដ្ឋប្រហារ បក្សយើងបានមាននយោបាយ

00809839

រណសិរ្សមួយស្រេចទៅហើយ ។ ក្រោយរដ្ឋប្រហារ បក្សយើងដឹកនាំតនយោបាយ រណសិរ្សនេះភ្លាម ។ ប្រជាជនភាគច្រើន ឥស្សរជនភាគច្រើននៅក្នុងប្រទេស មកក្នុងរណសិរ្ស ។ ចក្រពត្តិអាមេរិក និងពួកអាលន់ណុល ត្រូវឯកោពីមតិប្រជាជាតិ និងប្រជាជនទាំងមូល ។ គេឃើញច្បាស់ថា ពួកអាលន់ណុល វាធ្វើរដ្ឋប្រហារ ចូលដៃជាមួយចក្រពត្តិ អាមេរិក ដែលប្រជាជនប្រឆាំង យូរមកហើយ ។ ពេលនោះ បក្សលើកមាគ៌ារណសិរ្ស ប្រមូលកម្លាំងប្រជាជាតិធំទូលាយ ប្រឆាំងចក្រពត្តិអាមេរិកនិងបរិវារ ។ រណសិរ្សនេះ គឺបក្សដឹកនាំ កម្លាំងជាមូលដ្ឋាន ជាកម្លាំងបង្អែក គឺសម្ពន្ធភាពកម្មករ-កសិករ ។ សកលលោកឧបត្ថម្ភយើង ហើយឃើញកម្លាំងយើងច្បាស់ ។

ក្នុងសភាពការណ៍ហ្នឹង បក្សបានដឹកនាំវាយសំរុកភ្លាមៗ កម្លាំងប្រជាជន និងកងទ័ពបដិវត្ត ដែលបានហ្វឹកហ្វឺនក្នុងចលនាបដិវត្ត នយោបាយ និងអាវុធ បានធ្វើកុប្បកម្ម យកអំណាចតាមភូមិ-ឃុំ និងទូទាំងប្រទេស ។ ប្រជាជន-មហាជន បានងើបឡើងធ្វើមហាបាតុកម្ម មហាកុប្បកម្ម ទូទាំងប្រទេស ។ ដូច្នោះបដិវត្តវាយសំរុកទាំងនយោបាយ ទាំងយោធា ធ្វើឲ្យចក្រពត្តិអាមេរិកទាល់ច្រក ហើយអាលន់ណុល ក៏ទាល់ច្រកដែរ ។ ប្រជាជន



រាប់លាន ពីគ្រប់ទិសទី វាយសំរុកបុកចូលមកភ្នំពេញ បំរុងវាយអាលន់ណុល គំទេចចោល ។ ក្នុងរយៈមួយខែប៉ុណ្ណោះ យើងរំដោះភូមិ-ឃុំនិងទូទាំងប្រទេស ចំនួន៧០ទៅ៧៥ភាគរយ ។ ចក្រពត្តិអាមេរិក ឃើញសភាពការណ៍យ៉ាងនេះ វាក៏លើកកងទ័ព ចូលមកវាយយើងដោយផ្ទាល់ ។ វាចូលច្រើនម៉ឺន តាមព្រំប្រទល់ខាងកើតពីវៀតណាមខាងត្បូង ចូលមកវាយយើង ។ កងទ័ពចក្រពត្តិអាមេរិកសំបូរបែបជាងគេលើសលោក មានទាំងរថក្រោះ និងយន្តហោះគ្រប់បែបយ៉ាង ។ ពួកអាធីវគី ក៏ចូលមករាប់សែននាក់ ក្នុងទឹកដីកម្ពុជា មកវាយបដិវត្តកម្ពុជា ដើម្បីស្រោចស្រង់ ពួកអាក្បត់លន់ណុល ។ ដូច្នោះកម្លាំងក្បត់ នៅពេលនោះ មានអាលន់ណុល មានអាមេរិក មានអាធីវគី ។ ការដែលអាមេរិក និងពួកអាក្បត់ នៅវៀតណាមខាងត្បូង ចូលមកវាយកម្ពុជានេះហើយ ដែលយើងហៅថា «អាមេរិកូបនីយកម្មសង្គ្រាមទៅកម្ពុជា» និង «វៀតណាមូបនីយកម្មសង្គ្រាមទៅកម្ពុជា» ។ សភាពនេះខ្លាំងក្លា និងឃោរឃៅណាស់ ។ អាមេរិក វាចូលមកជាមួយអាធីវគី ដើម្បីយកកម្លាំងវាវាយយើង ហើយកសាង រៀបចំកម្លាំងអាណុល ដើម្បីអនុវត្តនយោបាយ ខ្មែរូបនីយកម្មសង្គ្រាម នៅកម្ពុជា តាមនយោបាយអានិចសុន យកខ្មែរវាយខ្មែរ ដោយវាជាអ្នកចេញលុយនិងអាវុធ ។

ក្នុងពេលហ្នឹង បើប្រៀបធៀបកម្លាំងខ្លាំង វាខ្លាំងណាស់ ព្រោះមាន
កម្លាំងអាមេរិកផង អាជីវតីផង ។ តែបក្សយើងឃើញថា បើវាយ
អាមេរិកជាប់ អាមេរិកក៏ត្រូវស្លាប់នៅកម្ពុជា ហើយបើវានៅយូរ កាន់
តែស្លាប់ច្រើនទៀត ដូច្នេះយើងវាយបាន វាមិនមែនខ្លាំងយូរ
ប៉ុន្មានទេ ។ ឯពួកអាជីវតី ក៏យើងវាយបាន ដោយសារម៉្យាង
កងទ័ពយើងធ្លាប់វាយវាហើយ ម៉្យាងទៀត ប្រជាជនយើងស្អប់
អាជីវតីសំបើមណាស់ ស្ទើរតែទាហានអាក្បត់លន់ណុល ក៏ឈ្លោះ
ជាមួយទាហានអាក្បត់អាជីវតីដែរ ។ បក្សយើង បានបំផុសស្មារតី
ស្នេហាជាតិ ឲ្យខ្ពង់ខ្ពស់ ដើម្បីវាយចក្រពត្តិអាមេរិកឈ្លានពាន
អាជីវតីឈ្លានពាន និងអាលន់ណុលក្បត់ជាតិ ហើយអំពាវនាវ
ប្រជាជនសកលលោក ជួយគាំទ្រប្រឆាំងចក្រពត្តិអាមេរិក និង
បរិវារ ។ យើងបានទទួលនូវការឧបត្ថម្ភពីសកលលោក យ៉ាង
សស្រាក់សស្រាំ រហូតដល់មានការជួយឧបត្ថម្ភពីប្រជាជនអាមេរិក
ផង ។ ដូច្នោះ របស់ដែលហៅថា «អាមេរិកូបនីយកម្មសង្គ្រាម
នៅកម្ពុជា» និង «វៀតណាមូបនីយកម្មសង្គ្រាមនៅកម្ពុជា»
បានត្រូវបរាជ័យយ៉ាងអាម៉ាស់មុខ ។

ព្រមជាមួយនឹងចលនាវាយសំរុកនៅសមរភូមិមុខ ក្នុងឆ្នាំ
១៩៧០នេះ បក្សក៏បានបើកចលនាមហាជននៅក្នុងតំបន់រំដោះបង្ក-



បង្កើនផល ដើម្បីឧបត្ថម្ភខ្លួនផង និងឧបត្ថម្ភដល់សង្គ្រាមបដិវត្តផង ។

ឆ្នាំ ១៩៧១ បក្សបានបើកមហាសន្និបាតបក្សលើកទី III ។ 71: 3rd Cong
ខ្លឹមសារសរុប នៃមហាសន្និបាតបក្សលើកទី III គឺបន្តធ្វើសង្គ្រាម
ប្រជាជន និងអនុវត្តមាគ៌ា សង្គ្រាមប្រជាជនរបស់បក្ស ប្រឆាំង
សង្គ្រាមឈ្លានពានចក្រពត្តិអាមេរិក និងបរិវារ ដើម្បីរំដោះកម្ពុជា
ឲ្យបានឯករាជ្យ សន្តិភាព អព្យាក្រឹត ។ ទន្ទឹមនឹងនេះ បន្តអនុវត្ត continue
នូវប្រជាធិបតេយ្យ វាយរំលំសក្តិភូមិ - ម្ចាស់ដី នាយទុនប្រតិកិរិយា implementing democracy
ដើម្បីរំដោះប្រជាជនទាំងមូល ពិសេសកសិករ ។ ការកិច្ចនេះនៅ ie, attacking
ក្នុងក្របខ័ណ្ឌ បដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យដដែល ។ បញ្ហា feudalists,
សំខាន់ ត្រូវរៀបចំកម្លាំងគ្រប់ផ្នែក ដើម្បីដំណើរការឲ្យបានខ្លាំង landlords,
ក្លា ។ ព្រមជាមួយគ្នានេះ មហាសន្និបាតបក្ស បានឯកភាពគ្នា reactionary capitalists
អំពីជ័យជំនះយ៉ាងធំ នៃមហាសន្និបាតបក្សលើកទី I និងលើកទី II
ដែលបានកំណត់ និងបានអនុវត្ត យ៉ាងត្រឹមត្រូវ នូវមាគ៌ាជា
យុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ។ ពន្លឺនៃមហា
សន្និបាតបក្ស លើកទី III បានធ្វើឲ្យបរាជ័យជាមូលដ្ឋាន នៃ
នយោបាយខ្មែរូបនីយកម្មសង្គ្រាម របស់ចក្រពត្តិអាមេរិក ក្នុងកិច្ច
ប្រតិបត្តិការចិន្លាទី II ។

ក្នុងឆ្នាំ ១៩៧២ ព្រមគ្នាជាមួយនឹងការវាយសំរុក នៅ

00809842



សមរភូមិមុខ នៅសមរភូមិក្រោយ បក្សបានចាប់ផ្ដើម បំផុស ចលនាតស៊ូកំចាត់ការទាក់ទងផលិតកម្មចាស់ ហើយកសាងការទាក់ទងផលិតកម្មថ្មី ដើម្បីជំរុញចលនាបង្កបង្កើនផល ឲ្យខ្លាំងក្លាថែមទៀត សំរាប់ឧបត្ថម្ភខ្លួន និងឧបត្ថម្ភសង្គ្រាមប្រជាជន ។ ព្រមជាមួយគ្នានេះ បក្សបានបំផុសប្រជាជន ប្រយុទ្ធជាមួយវណ្ណៈនាយទុន ដើម្បីបក្សក្ដាប់ពាណិជ្ជកម្មនៅក្នុងដៃ ។ ក្នុងឆ្នាំ ១៩៧២ នេះ ចលនាវាយខ្មាំងនៅសមរភូមិមុខ ក៏ខ្លាំងក្លា ចលនាតស៊ូវណ្ណៈនៅក្នុងតំបន់រំដោះ ទូទាំងប្រទេស ក៏ឡើងខ្ពស់មួយកំរិតថែមទៀត ។ ក្នុងចលនាក្ដៅគគុក ទាំងសមរភូមិមុខ និងសមរភូមិក្រោយនេះ កម្លាំងបដិវត្តរបស់បក្សគ្រប់ផ្នែក ក៏បានពង្រឹងនិងពង្រីកថែមទៀត ជាពិសេស កម្លាំងសម្ពន្ធភាពកម្មករ-កសិករ ។

ឆ្នាំ១៩៧៣ បក្សពិនិត្យឃើញច្បាស់ ថាខ្មាំងវាឡោយ កំលើកគោលការណ៍ វាយសំរុកខ្លាំងជាយុទ្ធសាស្ត្រ ពិតមែនតែយើងទើបនឹងមានកម្លាំង ត្រឹមវរសេនាធំ យើងវាយរហូត ទាំងប្រាំង ទាំងវស្សា ។ ទិសសំខាន់ គឺវាយខ្សែរូបនីយកម្មសង្គ្រាម ។ កាលណាកងទ័ពអាក្បត់ត្រូវខ្ទេចខ្ទី ចក្រពត្តិអាមេរិក គ្មានកម្លាំងមូលដ្ឋានជាជំនួយអី នៅក្នុងប្រទេសទេ ព្រោះអាមេរិក វាឈ្លានពានប្រទេសមួយៗ វាសង្ឃឹមលើកម្លាំងពួកអាក្បត់ ដូច្នេះ យើងវាយ

73: only segments exist



កម្លាំងពួកអាក្បត់ឲ្យខ្ទេចខ្ទី វាយវាទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ច ឲ្យវាហត់ហោរហែនទៀត ។ ពួកអាក្បត់អស់មនុស្សចាប់ធ្វើទាហាន ពីព្រោះប្រជាជន នៅខាងយើងអស់ ។ កសិករនៅនឹងយើងទាំងអស់ ។ ប្រជាជនក្រីក្រភាគច្រើន នៅខាងយើង ។ ឯពួកស្រទាប់កណ្ដាល ក៏នៅខាងយើង ។ ខ្មាំងអស់កម្លាំងមនុស្សពង្រីកទាហានវា ។ ដោយយើងមានមាគ៌ាពង្រឹងប្រជាជនពីខ្មាំង ដូច្នោះ មួយឆ្នាំកាន់តែអស់ មួយឆ្នាំកាន់តែអស់ ។ អស់ប្រជាជន គឺអស់សេដ្ឋកិច្ច អស់កម្លាំងយោធា អស់កម្លាំងនយោបាយ ដូច្នោះ ពួកអាក្បត់ត្រូវឯកោដល់កំរិតយ៉ាងខ្ពស់បំផុត ។ ព្រមជាមួយគ្នានេះ ក្នុងឆ្នាំ ១៩៧៣ដដែល ចលនាសហករណ៍រូបនីយកម្មនៅជនបទ ក៏បានពង្រីកយ៉ាងខ្លាំងក្លា ធ្វើឲ្យកម្លាំងសមរភូមិក្រោយ កាន់តែបានពង្រឹង និងពង្រីកជាមូលដ្ឋានរឹងមាំ សំរាប់សមរភូមិមុខ ។ ចលនាជីកប្រឡាយ ធ្វើទំនប់ ជីកស្រះ ។ល។ ចលនាធ្វើស្រែប្រាំង ស្រែវស្សា ដាំដំណាំយុទ្ធសាស្ត្រ ផុលផុសកាន់តែខ្លាំងក្លា បំរើសង្គ្រាមប្រជាជន និងជំរុញសង្គ្រាមប្រជាជន ទៅកាន់ជ័យជំនះ ជាបន្តបន្ទាប់ ។ ម្យ៉ាងទៀត ឆ្នាំ១៩៧៣ ក៏ជាឆ្នាំដែលចក្រពត្តិអាមេរិកកាំង ត្រូវបរាជ័យយ៉ាងអាម៉ាស់ នូវសង្គ្រាមអាកាសរបស់វា មកលើប្រទេសកម្ពុជាយើង ។ ដូច្នោះ ចក្រពត្តិអាមេរិក ត្រឡប់មក

73: middle classes are w/ revolution

អនុវត្តនយោបាយ ខ្មែរូបនីយកម្មសង្គ្រាមវិញទៀត ដោយផ្គត់ផ្គង់សំភារៈសឹក សេដ្ឋកិច្ច-ហិរញ្ញវត្ថុ គ្រប់បែបយ៉ាង ឲ្យពួកអាក្បត់លន់ណុលនៅភ្នំពេញ តែចក្រពត្តិអាមេរិក មិនអាចស្តារកម្លាំងពួកអាក្បត់ ដែលកាន់តែខ្សោះអស់ឈាមបានឡើយ ។

កណ្តាលឆ្នាំ ១៩៧៤ បក្សបានកំណត់បើកការវាយសំរុកជាយុទ្ធសាស្ត្រ ដើម្បីផ្តាច់ព្រ័ត្រវំដោះទូទាំងប្រទេស ។ បក្សបានកំណត់វាយផ្ចួតទៅនេះ ៖

— វាយមេកុងក្រោមជាគន្លឹះ ដើម្បីផ្តាច់ស្បៀង ផ្តាច់ផ្លូវគមនាគមន៍របស់ខ្មាំង

— វាយជុំវិញភ្នំពេញ ដើម្បីវាយផ្តាច់ភ្នំពេញ

— បើកវាយទីរួមខេត្តខ្លះ ដែលខ្មាំងកាន់កាប់បណ្តោះអាសន្ន ដើម្បីរួមជុំ ។

— វាយទាំងអស់ព្រមជាមួយគ្នា កុំឲ្យខ្មាំងដកកម្លាំងទៅជួយគ្នាបាន

ដល់ចុងឆ្នាំ១៩៧៤ បក្សបានលំអិត និងលំអថែម នូវសេចក្តីសំរេចចិត្ត ដែលកំណត់បើកការវាយសំរុក ជាយុទ្ធសាស្ត្រពីពាក់កណ្តាលឆ្នាំ ១៩៧៤ ដោយបញ្ជាក់ច្បាស់ ថាត្រូវតែផ្តេជ្រាបចិត្តបញ្ចប់សង្គ្រាមឈ្លានពាន របស់ចក្រពត្តិអាមេរិក និងបញ្ចប់វាសនា



ពួកអាក្បត់នៅភ្នំពេញ ក្នុងរដូវប្រាំង១៩៧៥ ។ ទូទាំងប្រទេសត្រូវបើកឆាកវាយសំរុកឲ្យព្រម១គ្នា ឲ្យខ្មាំងក្លាជាប់ជានិច្ច និងវាយឲ្យចំទិស តាំងពីថ្ងៃទី១ ខែ១ ឆ្នាំ ១៩៧៥ ។

ដាច់ឆ្នាំ១៩៧៤ ។ វេលាសូន្យម៉ោង ថ្ងៃទី១មករា ឆ្នាំ១៩៧៥ ទូទាំងប្រទេស ផ្ទុះអាវុធ បើកឆាកវាយសំរុកតាមផែនការកំណត់ របស់បក្ស ។ ក្នុងមួយរយៈពេលដ៏ខ្លីនៃខែ១ យើងកំទេចទីតាំង និងកម្លាំងរស់របស់ខ្មាំងបានយ៉ាងសំបើម នៅជុំវិញភ្នំពេញ នៅតាមផ្លូវគមនាគមន៍ជាយុទ្ធសាស្ត្រ ទាំងដើងទឹកទាំងដើងគោក និងនៅតាមខេត្តមួយចំនួន ដែលខ្មាំងកាន់កាប់បណ្តោះអាសន្ន ។

ចូលខែ២ ឆ្នាំ១៩៧៥ ចិត្តការពួរបស់ខ្មាំង គឺខ្មាំងកាន់តែបាក់ខ្លាំងឡើង១ ។ វាស្ថិតក្នុងសភាពស្លូឈាមទូទាំងប្រទេស ។ 2/75 enemy is broken ខ្មាំងខ្សោយខ្លាំងមែនទែន ។ នៅមេកុង វាត្រូវខូចខ្ទីជាមូលដ្ឋានទាំងកម្លាំងរស់ ទាំងទីតាំង ទាំងសំភារៈ ។ សមរភូមិជុំវិញភ្នំពេញខ្មាំងស្លូឈាមមួយកំរិតធំថែមទៀត ព្រោះអស់កម្លាំងរស់ អស់ទីតាំងមួយកំរិតធំទៀត ដើម្បីការពារភ្នំពេញ ។ មធ្យោបាយសឹក ក៏ត្រូវអន្តរាយច្រើន ទាំងយន្តហោះ រថក្រោះ កាំភ្លើងធំ ។ ចំណែកកម្លាំងដែលវាយកមកពីខេត្ត ក៏ចុះប៉ូវមិនបាន គឺគ្រាន់តែទប់១ជាបណ្តោះអាសន្ន តែកម្លាំងនេះ ក៏ត្រូវខូចខ្ទីជាបណ្តីរទៀត ។

00809844



នៅសមរភូមិទីរួមខេត្តនានា ខ្មាំងក៏ត្រូវបាក់តាំងផ្ទាំងៗ គ្មានកម្លាំងជំនួយ ហើយថែមទាំងអស់ប្រាយទៀត ។

ខាងនយោបាយ ឧបករណ៍អាក្សត់និងបក្សពួកវា ពោលតែពីរឿងស្លាប់ៗ ចក្រពត្តិអាមេរិកសារភាពថា វាអស់សង្ឃឹមពេញទីៗ ចលនាតស៊ូរបស់ប្រជាជន នៅទីក្រុងភ្នំពេញ នៅបាត់ដំបង កាន់តែខ្លាំងក្លា ។ ក្នាត់ផ្កាទូត និងអន្តការបរទេសផ្សេងៗ និងអាណិកជនបរទេស នាំគ្នារត់ចេញពីភ្នំពេញ អត់មានសង្ឃឹមលើពួកអាក្សត់ទេ ។

people's urban struggle movements

ខាងសេដ្ឋកិច្ចវិញ ក្នុងខែ២នេះ លុយក៏អស់រលីង ជំនួយអាមេរិកថែមមកទៀត ក៏មិនគ្រប់ ។ រកតែលុយបើកប្រាក់ខែក៏គ្មាន ។ អង្ករក៏អស់រលីង ។ បញ្ហាដឹកពីក្រោមក៏អត់ទៀត ។ ចូលខែ ៣ ឆ្នាំ១៩៧៥ ខ្មាំងបាត់ម្ចាស់ការ ស្ទើរតែអស់រលីង ទាំងយោធា នយោបាយ សេដ្ឋកិច្ច ។

ថ្ងៃ ១ខែ ៤ ឆ្នាំ ១៩៧៥ យើងរំដោះនាក់លឿង ។ អាក្សត់លង់ណុល រត់ចោលស្រុក ។ កងទ័ពបដិវត្តស្ថិតនៅក្នុងឋានៈម្ចាស់ការទាំងស្រុង បន្តការវាយសំរុកយ៉ាងខ្លាំងក្លា ចូលរំដោះភ្នំពេញ ។

ថ្ងៃ១២មេសា១៩៧៥ ទូតចក្រពត្តិអាមេរិក និងបុគ្គលិក



វារត់ជាសំក្រញា ឡើងឧទ្ធម្ភាគចក្រយ៉ាងអាម៉ាស់មុខ ។

ថ្ងៃ១៧មេសា១៩៧៥ យើងរំដោះភ្នំពេញ រំដោះទូទាំងប្រទេស បានទាំងស្រុង ។ បដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យបានបញ្ចប់ ដោយមហាជោគជ័យ មហាអស្ចារ្យ ក្រោមពន្លឺដ៏ត្រចះត្រចង់ នៃមាគ៌ាជាយុទ្ធសាស្ត្រ នៃបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ នៃមហាសន្និបាតបក្សលើកទី I និងមហាសន្និបាតបក្សលើកទី II លើកទី III ជាបន្តបន្ទាប់ ។

17/4/75 national democratic revolution completed

NB: no significant mention of local administration: all military matters emphasized instead

## មេរៀនធំៗមួយចំនួន ក្នុងរយៈកាលឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានដូចតទៅ

### ១. អំពីការកសាងកម្លាំងបក្ស ដឹកនាំ សង្គ្រាមប្រជាជនរំដោះជាតិ រំដោះប្រជាជន

NB: no mention of Vietnamese assistance except for vague references to international support

បញ្ហានេះ មានសារៈសំខាន់ជាងគេបំផុត ។ បើបក្សដឹកនាំត្រឹមត្រូវតាមមាគ៌ា គឺពិតជាបានជ័យជំនះ ។ បើដឹកនាំខុសមាគ៌ា ពិតជាបរាជ័យ ។

ergo: lessons do not follow from reality

## I. ការរៀបចំកម្លាំងបក្ស ខាងនយោបាយ

តាមទិដ្ឋភាព ជាពិសោធន៍ផ្សេងៗមួយចំនួន ក្នុងការ ដឹកនាំបក្សដឹកនាំសង្គ្រាមបដិវត្ត ពីឆ្នាំ ១៩៧០ ដល់ ១៩៧៥ មាន ទិដ្ឋភាពប្រយុទ្ធខាងទស្សនៈនយោបាយ និងមាគ៌ានយោបាយជា បន្តបន្ទាប់ រវាងបក្សយើង និងពលានុភាពសត្រូវនានា នៅលើ សកលលោក ប្រទង់ប្រទាញគ្នាតឹងតែង ស្វិតស្វាញ ជ្រាលជ្រៅ ណាស់ៗ ទិដ្ឋភាពមួយចំនួនគឺ មាគ៌ានយោបាយបក្សយើង ដោយ ឈរលើពិសោធន៍ ជាបន្តបន្ទាប់មក យើងឈរលើគោលជំហរ ឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ជាសំខាន់ៗ ព្រមជាមួយគ្នានេះ ក៏ប្រមូលកម្លាំងសកលលោក ដើម្បីឧបត្ថម្ភយើងដែរ តែជាមូលដ្ឋាន និងជាកត្តាកំណត់ គឺត្រូវខ្លួនឧបត្ថម្ភខ្លួន លើគ្រប់ផ្នែកទាំងអស់ៗ ឈរលើគោលជំហរនេះ យើងរៀបចំបក្ស កងទ័ពបដិវត្ត រដ្ឋ-អំណាច ប្រជាជន សេដ្ឋកិច្ច មូលដ្ឋានបផ្អែក វប្បធម៌-សង្គមកិច្ច ការងារបរទេស ។ល។ ។ តែគោលជំហរនេះ ត្រូវកម្លាំងខាង ក្រៅតស៊ូសង្កត់ជាច្រើន ដោយមិនសូវយល់គោលជំហរនេះ ខ្លះ ប្រឆាំងទៀត ព្រោះទស្សនៈខុសគ្នា ។ គេយល់ថា យើងតូច ពុំអាចឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន បានទេ ត្រូវពឹងផ្អែក លើសកលលោក ។ បញ្ហានេះ មានការប្រយុទ្ធគ្នា ជាទស្សនៈ

Vietnamese and Chinese objections

to independence mastery - self reliance

ideological/organi-zational struggle w/ external forces



ក្រោយការច្រូតកាត់ ពោកថែនប្រមូលទុកដាក់ផលរួចហើយ យុវជន-យុវនារី និង កម្មាភិបាលបដិវត្តយើង នាំគ្នាចុះប្រឡូកជាមួយកសិករសហករណ៍ ប្រយុទ្ធ ជីកប្រឡាយ លើកភ្លឺថ្មី ត្រៀមលក្ខណៈសម្បត្តិវាយសំរុកធ្វើស្រែ ជនរដូវវស្សាខាងមុខនេះ ឱ្យបាន ៣ តោន ១ ហិកតា ជាមធ្យម ។ រូបនេះ សមាជិកសហករណ៍ ភូមិអន្លង់ទៀន ស្រុកព្រពាំងផង ខេត្តពោធិសាត់ កំពុងវាយសំរុកជីកប្រឡាយមេធំមួយ ដើម្បីនាំទឹកបញ្ចូលស្រែ ។

irrigation works in Posat to achieve 3tons/ha average

គោលជំហរ រហូតដល់ចាត់តាំង ។ យើងសុខចិត្តសាមគ្គីជាមួយ
សកលលោក តែដាច់ខាត យើងត្រូវឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភ
ខ្លួន ខ្លួនក្តាប់វាសនាប្រទេសជាតិខ្លួន ដោយខ្លួនឯង ទើបសាមគ្គី
ជាមួយសកលលោកបានល្អ ។ ពិសោធន៍របស់យើងគឺ ទោះបីជា
បក្សយើងតូច ប្រជាជនយើងតិច តែបើមានមាគ៌ាត្រឹមត្រូវ ហើយ
ឯកភាពគ្នាជាធ្លុងមួយនៅក្នុងបក្ស ក្នុងប្រជាជន និងក្នុងកងទ័ព
នោះគឺពិតជាឈ្នះដាច់ខាត ។ នៅក្នុងបក្ស ក៏មានកម្លាំងប្រឆាំង
មួយចំនួនតិច ដែលទទួលឥទ្ធិពលពីបរទេស ។ តែមជ្ឈិមបក្ស
ក្តាប់បញ្ហានេះបាន ហើយផ្សព្វផ្សាយទូទាំងប្រទេស ឯពួក
ប្រឆាំងនេះ ដល់កំរិតខ្ពស់ រហូតដល់ពួកវាចេញមុខប្រឆាំងចំហ
បកអាក្រាតមុខមាត់ក្បត់របស់វា ។ ក្រៅពីនេះ មានសមាសភាពខ្លះ
ទៀតដែរ តែមួយចំនួនតិច ច្រើនអ្នកមិនជាប់ចលនា មិនយល់
ចលនា មិនមានពិសោធន៍ដោយខ្លួនឯង ហើយបុគ្គលនិយម សួនតួ
និយមខ្ពស់ ក៏មានប្រតិកិរិយាមិនសមរម្យ ចំពោះមាគ៌ារបស់
បក្សនេះ ។

internal sceptics unmasked as traitors
1) those influenced by foreigners
2) those not directly involved

## តើពិសោធន៍អ្វី ដែលនាំឲ្យយើងឯករាជ-ម្ចាស់ការ

ខ្លួនឧបត្ថម្ភខ្លួន ? គឺពិសោធន៍ជាក់ស្តែង នៃចលនាមហាជនយើង
និងពិសោធន៍ជាក់ស្តែងក្នុងសកលលោក ដូចជាពិសោធន៍កាលវាយ

SIC

obviously, this is contentious; and exposition is tendentious

00809847



ផាកំង ពិសោធន៍កិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ ១៩៥៤ ពិសោធន៍កិច្ចព្រមព្រៀងប៉ារីស ស្តីអំពីបញ្ហាវៀតណាមឆ្នាំ ១៩៧៣ ។ល។ ទាល់តែខ្លួនឯង ធ្វើបដិវត្តខ្លួនឯង គិតមាគ៌ាបដិវត្តដោយខ្លួនឯង ទទួលខុសត្រូវខ្លួនឯងដោយស្មារតីខ្ពស់ ទើបឯករាជ្យ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន បានរឹងមាំ ។

មានចលនាហើយដកពិសោធន៍ពីចលនា រៀនពីចលនា សុភាពកបសាដាក់ខ្លួនក្រោមចលនា នេះជាបញ្ហាគន្លឹះមួយ ដើម្បីពង្រឹងទស្សនៈគោលជំហរ មាគ៌ារបស់បក្សយើង ។ ដូច្នេះ ត្រូវសុភាពកបសា រៀនសូត្រពីចលនាមហាជន ។ ត្រូវរៀនសូត្រចលនាដើម្បីយល់មាគ៌ា និងកែតំរង់មាគ៌ា ។ ដូច្នេះ កុំដាច់ពីមូលដ្ឋាន កុំដាច់ពីចលនា កុំដាច់ពីប្រជាជន នៅមូលដ្ឋានភូមិ-ឃុំ កុំដាច់ពីសហករណ៍ ។

2. ការរៀបចំកម្លាំងបក្ស ខាងសតិអារម្មណ៍

no reconciliation w/ ideological error

មានមាគ៌ាហើយ ត្រូវមានសតិអារម្មណ៍ប្រយុទ្ធដាច់ខាត មិនស៊ីសស្ពាស មិនរួមរស់ មិនសំរុះសំរួល ជាមួយសតិអារម្មណ៍ខុសឆ្គង ។

ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ បក្សយើងប្រយុទ្ធកសាង



សតិអារម្មណ៍យ៉ាងម៉េច ? ការប្រយុទ្ធរវាងសតិអារម្មណ៍បដិវត្ត និងមិនបដិវត្ត រវាងសតិអារម្មណ៍តស៊ូដាច់ខាត និងសតិអារម្មណ៍សំរុះសំរួល បានប្រយុទ្ធជាប់រហូត ហើយមិនមែនជាការងាយស្រួលទេ ។ វាមានសភាពតឹងតែង ស្មុគស្មាញ លំបាកជាងនយោបាយទៅទៀត ។ យើងបានដកពិសោធន៍ពីឆ្នាំ១៩៧០មក ដូចជាសតិអារម្មណ៍ក្អេងក្អៀង កម្មសិទ្ធិបុគ្គល សួនតួ ខាងសំភារៈនិងអំណាច សតិអារម្មណ៍មិនអធន់ នៅប្រឡូកប្រឡាក់ច្រើននៅឡើយ ។ ទន្ទឹមនឹងនេះ គោលជំហរវណ្ណៈអធន់ នៅមិនទាន់បានពង្រឹងពង្រីកនៅឡើយទេ ។ សតិអារម្មណ៍នេះ ពាក់ព័ន្ធដល់ការកិច្ចធ្វើសង្គ្រាម រំដោះជាតិ រំដោះប្រជាជន ។ ដូច្នេះ បក្សប្រយុទ្ធកំចាត់នូវសតិអារម្មណ៍ខុសឆ្គង និងកសាងសតិអារម្មណ៍នៃវណ្ណៈអធន់ជាប់ជានិច្ច ។

constant ideological struggle vs 1) happy-go-lucky 2) individualism 3) non-proletarian

eliminate ideological error

សន្និបាតមជ្ឈិមបក្ស ខែ៥ ឆ្នាំ១៩៧២ បក្សយើងបើកឆាកប្រកាសភាសន្ទ នៃគោលជំហរមិនអធន់ ដែលមាននៅក្នុងបក្ស ។ ខ្លឹមសារជាស្នូលធ្វើជាឯកសារអប់រំ គឺបញ្ហាវណ្ណៈ និងតស៊ូវណ្ណៈ បញ្ហាផ្តាច់ការវណ្ណៈអធន់របស់បក្ស សំភារៈនិយមបដិច្ចសមុប្បាទ និងសំភារៈនិយមប្រវត្តិសាស្ត្រ ។ ព្រមជាមួយគ្នានេះ បក្សបានបើកឆាករៀបចំសហករណ៍ ជាជំហានដំបូង

72-73 class struggle inside party and among masses

but class struggle continues inside party

ដូច្នេះ មានជាបលនាផុលផុសក្នុងមហាជន និងទូទាំងប្រទេស ។ ដល់ពាក់កណ្តាលឆ្នាំ១៩៧៣ មជ្ឈឹមបក្សបើកសន្និបាតទៀត ពិនិត្យអំពីការតស៊ូវណ្ណៈនៅក្នុងបក្ស និងក្នុងមហាជន ។ ជំនះមួយដំហាននេះដែរ តែក៏នៅមានសតិអារម្មណ៍ អនុធន សក្តិភូមិ នាយទុននិងសតិអារម្មណ៍ នៃវណ្ណៈមិនបដិវត្តឯទៀត តាមបាតុភាពផ្សេងៗនៅក្នុងបក្ស រដ្ឋអំណាច កងទ័ព ល្អបៗលៗ យើងបន្តការប្រយុទ្ធតទៅទៀត ដោយរៀនសូត្រពលនា ។ ការខ្វះខាត ក៏នៅមានជាធ្ងន់ ជាស្រាល ។ ការកសាងសតិអារម្មណ៍ នៃវណ្ណៈអធន មិនទាន់ត្រឹមត្រូវ ។

pacification by war works

ដោយការតស៊ូកសាងយ៉ាងនេះ ទើបបំពេញការកិច្ចប្រជាជាតិ-ប្រជាធិបតេយ្យពេលនោះបាន ។ ដើមឆ្នាំ១៩៧៤ មានបញ្ហាកើតជាច្រើន ដោយខ្មាំងធ្វើសន្តិសម្ព័ន្ធ ធ្វើឲ្យខូចខាតខ្លះដល់កងទ័ព រដ្ឋអំណាច តម្កាកិបាលមួយចំនួន ប៉ះពាល់ដល់ពលនាមួយកំរិតដែរ ធ្វើឲ្យខូចខាតសមរភូមិមុខមួយចំនួន ។ មូលហេតុ មកពីគោលជំហរអធន នៅស្រពិចស្រពិល យោលយោងៗ

mid-74 party expansion suspended

នៅពាក់កណ្តាលឆ្នាំ១៩៧៤ បក្សបានប្រើវិធានការចាត់តាំង គឺផ្អាកពង្រីកបក្ស និងអង្គការសំងាត់សិន ។ ពិសោធន៍នេះ យើងបានទិតទំកសាង នៅឆ្នាំ១៩៧៤-៧៣ ខ្មាំងដែរ តែដល់ខ្មាំងវាយ

= organizational measures



មកវិញ ខាងគោលជំហរស៊ីលធម៌បដិវត្ត នាំឲ្យយើងខូចខាតខ្លះដែរ ។

យើងរៀបចំសតិអារម្មណ៍ ដើម្បីជាធានាដល់ការដឹកនាំទៅសមរភូមិមុខ និងសមរភូមិក្រោយ ត្រៀមវាយផ្តាច់ព្រ័ត្រនៅរដូវប្រាំងឆ្នាំ១៩៧៥ ។

ពិសោធន៍អំពីការងារសតិអារម្មណ៍ ឃើញថា :

ideological struggle must continue

១. សតិអារម្មណ៍ ក៏ប្រែប្រួលជាប់ យើងត្រូវធ្វើការងារសតិអារម្មណ៍ជាប់ ។ កន្លងមក យើងធ្វើបានមួយគំរិត តែវាយទៅវិញ ដូច្នេះ ត្រូវធ្វើជាប់ជានិច្ច កុំអត្តនោម័តិ ។

proletarian ideology summed up

២. ខ្លឹមសារសតិអារម្មណ៍ ដែលបក្សសំរុកកសាងមានច្រើន តែទាំងអស់នេះ សរុបទៅ គឺសតិអារម្មណ៍នៃវណ្ណៈអធន គោលជំហរនៃវណ្ណៈអធន ។

- អធន គ្មានអ្វីទាំងអស់ ទាំងសំភារៈ អំណាច កម្មសិទ្ធិខាងបុគ្គល កម្មសិទ្ធិទស្សនៈ — 1) prols have nothing
- មានការចាត់តាំងខ្ពស់បំផុត គឺគោរពវិន័យអង្គការខ្ពស់ — 2) highly organized
- ផលិតកម្មចំរើនលឿនលឿន ខ្ពង់ខ្ពស់ — 3) highly productive and creative

ព្រមជាមួយគ្នានេះ ឯកសារសំភារៈនិយមបដិវត្តសម្បូរ

និងសំការៈនិយមប្រវត្តិសាស្ត្រ ក៏ជួយពង្រឹង ខ្លះគោលជំហរវណ្ណៈ
អធន ច្រើនដែរ ។

៣. ផ្អែកលើចលនាបដិវត្តរបស់មហាជន តាំងក្នុងបក្ស កងទ័ព ប្រជាជន ដែលគេធ្វើចលនាបដិវត្តគ្រប់ទីកន្លែង មានសតិអារម្មណ៍ខុស-ត្រូវយ៉ាងម៉េច យើងយកចលនាតាំងនេះ មករៀនសូត្រ បំពាក់បំប៉ននៅក្នុងបក្សតាំងមូល

Building the Party organizationally

3. ការកសាងកម្លាំងបក្ស ខាងចាត់តាំង

មានមាគ៌ាត្រឹមត្រូវ មានសតិអារម្មណ៍នៃវណ្ណៈអធនល្អ ហើយ ត្រូវរៀបចំការចាត់តាំង ឲ្យត្រឹមត្រូវ រៀបរយតាំងអស់ តាំងបក្ស កងទ័ព ប្រជាជន រដ្ឋអំណាច មន្ទីរផ្សេងៗ ។ល។

តើរៀបរយយ៉ាងណា ?

១. មាគ៌ាចាត់តាំងរបស់បក្ស ផ្អែកលើមាគ៌ាវណ្ណៈជាមូលដ្ឋាន ទាល់តែផ្អែកលើមាគ៌ាវណ្ណៈរបស់បក្ស ទើបអនុវត្តមាគ៌ានយោបាយរបស់បក្សបាន ។

ក្នុងន័យអនុវត្ត មាន២យ៉ាង :

ម្យ៉ាង គឺអ្នកដែលចូលមកក្នុងជួរហើយ ត្រូវបំពាក់បំប៉ន គោលជំហរវណ្ណៈអធនឲ្យគេ ដើម្បីគេបំរើបក្សឲ្យបានត្រឹមត្រូវ ។

ម្យ៉ាងទៀត ក្នុងការជ្រើសរើសថ្មី ត្រូវផ្អែកលើវណ្ណៈមូលដ្ឋាន ។

ideologically nurture existing members
accept only class-proper new members

to prevent opportunism & infiltration



ដោយមាគ៌ាចាត់តាំងរបស់បក្សយ៉ាងនេះ យើងទប់ទល់សមាសភាពឱកាសនិយមបាន ទប់ទល់សកម្មភាពខ្មាំង ចូលស៊ីរូងផ្ទៃក្នុង បានជាអតិបរមា ។

២. មាគ៌ាចាត់តាំងតាមលក្ខការណ៍ផ្សេងៗរបស់បក្ស គឺ ៖

— ចេញពីចលនាបដិវត្ត សាកល្បងច្រើនលើក ច្រើនសាក្នុងចលនាបដិវត្ត from the movement to the movement
— វណ្ណភាពល្អ class background
— សីលធម៌បដិវត្តល្អ តាំងការរស់នៅ តាំងនយោបាយ good revolutionary morals
— សភាពការណ៍ចាត់តាំងរបស់បក្សយើង ដល់ថ្ងៃនេះ មានទិដ្ឋភាព២ ៖

ម្យ៉ាង មានការរីកចំរើននាំឲ្យធំធាត់ តែម្យ៉ាងទៀត គឺនៅមិនទាន់បរិសុទ្ធតាំងក្នុងបក្ស កងទ័ព អង្គការមហាជន តាមក្រសួង-មន្ទីរផ្សេងៗ។ល។ នេះជាទិដ្ឋភាពទុះទាត ដើម្បីបន្តការរៀបចំ ចាត់តាំងតទៅទៀត ដើម្បីទប់ទល់សកម្មភាពខ្មាំងជាចក្រពត្តិ ជាសំណល់នៃវណ្ណៈសក្តិភូមិ នាយទុន ពួកបំផ្លាញបដិវត្តផ្សេងៗទៀត ។

party has grown but remains impure

because of imperialist feudalist and capitalist class remnants and other wreckers

ពិសោធន៍មួយចំនួន បានបង្ហាញឲ្យយើងឃើញថា ៖

but don't be narrow in recruiting

1. ដើម្បីពង្រីកពង្រីកការចាត់តាំង ឲ្យល្អ ស្អាតស្អំ ត្រូវផ្អែកលើចលនាមហាជន ៗ កុំជ្រើសរើសសំរិតសំរាំង ពង្រីកពង្រីក ដោយគ្រប់វិធីណ្ឌបង្អៀត ប្តូរថ្នាក់ណាមួយ ៗ ត្រូវយកចលនាមហាជន ជាបន្តបន្ទាប់និច្ច័យ ៗ

2. ការពង្រីកនិងពង្រីក អង្គការចាត់តាំងរបស់បក្ស ឬក្នុងផ្លូវបដិវត្តទាំងអស់ ត្រូវធ្វើឡើងដោយអនុវត្តមាគ៌ាចាត់តាំងរបស់បក្ស ជាបន្តបន្ទាប់ តាមមាគ៌ាចាត់តាំងវណ្ណៈ និងលក្ខការណ៍ចាត់តាំងរបស់បក្ស កុំធ្វើតែមួយដងមួយកាល ហើយឈប់ទៅវិញ ៗ don't backslide

opportunists and happenstance

3. សមាសភាពទៃ ជាឱកាសនិយម ជាពួកចៃដន្យ

watch out for those seperated from the movement or w/unclear bios

ពួកមិនជាប់និងចលនា ប្រវត្តិរូបមិនច្បាស់លាស់ ជាខ្សែសង្វាក់ ត្រូវប្រុងប្រយ័ត្នជាអតិបរមា ហើយឈរលើការប្រុងប្រយ័ត្ននេះ យើងសាកល្បងជាបណ្តើរៗ កុំប្រគល់ការងារធំៗឲ្យពិនិត្យតាមដានជាបន្តបន្ទាប់ ហើយក្នុងរយៈពេលយូរ ៗ តាមពិសោធន៍សមាសភាពនេះ បំរើចលនាមិនបាន ហើយគ្រោះថ្នាក់ដល់ចលនាបដិវត្តទៀត ។



enemies always have plans

4. លើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្ត ឲ្យខ្ពស់បំផុតខាងចាត់តាំង ព្រោះខ្មាំងគ្រប់ប្រភេទ ទាំងក្នុងទាំងក្រៅ ក៏មានផែនការបំផ្លិចបំផ្លាញយើងជាយុទ្ធសាស្ត្រ រាប់ផែនការ ៗ

new tasks mean party building must continue

ភារកិច្ចការពារប្រទេស និងកសាងប្រទេស នៅធ្ងន់ធ្ងរណាស់ ត្រូវបន្តការកសាងបក្ស ខាងគោលជំហរនយោបាយ សតិអារម្មណ៍ ឲ្យខ្លាំងក្លាជានិច្ច ក្នុងរយៈកាលថ្មីនេះ

២. ការកសាងកម្លាំងប្រជាជន និងកសាងកម្លាំងរណសិរ្សប្រជាជាតិ-ប្រជាធិបតេយ្យ ដើម្បីធ្វើជាកម្លាំង អនុវត្តភារកិច្ចបដិវត្ត ប្រជាជាតិប្រជាធិបតេយ្យ តាមសង្គ្រាមរំដោះជាតិរំដោះប្រជាជន

popular consciousness is not revolutionary

ប្រជាជនបានចូល ប្រឡូកក្នុងសង្គ្រាមរំដោះជាតិ តែជាដំបូង នៅមិនទាន់ខ្លាំងក្លានៅឡើយទេ

— ខាងនយោបាយ នៅយល់ត្រឹមថារួមគ្នា វាយចក្រពត្តិអាមេរិក និងពួកអាក្សត់ លន់ណុល

ខ្សោយ: គោលជំហរគេ នៅមិនទាន់បដិវត្តឲ្យជ្រៅជ្រះ

— ការផលិតកម្ម នៅឯកជន

— ពេលទូរខាត គេនៅពឹងពាក់លើម្ចាស់ដី អ្នកស្រែមាន ពឹងលើនាយទុន លើឈ្មួញនៅឡើយ

— ដូច្នោះ បានជាបក្សមានផែនការរៀបចំ ។ ពេលនោះ យកពានការទាត់គាំងជាគន្លះ គឺក្តាប់ពាណិជ្ជកម្ម ដោយក្តាប់បញ្ហាជាមុន ហើយឈានមកក្តាប់បញ្ហាផ្សេងៗឯទៀត ។

— រំសាយផ្សារ ដើម្បីកុំឲ្យនាយទុន ក្តាប់ផ្សារបំរើកបាន ។

— រៀបចំការទាក់ទងផលិតកម្មថ្មី ដោយកាយកំចាត់ការទាក់ទងផលិតកម្មចាស់ កសាងការទាក់ទងផលិតកម្មថ្មី នៅតំបន់រំដោះប្រភេទទី១ និងទី២ តាមកំរិតខ្ពស់-ទាបជាក់ស្តែង តាមសភាពការណ៍

— យកដីធ្លីពីពួកក្បត់ និងដីធ្លីដែលនៅសល់ ចែកឲ្យកសិករក្រ និង កសិករកណ្តាលថ្នាក់ក្រោម បង្កើនផល

— ចាត់តាំងសហករណ៍

solution is organizational measures

including setting up coops, abolishing markets



by making people dependent on the revolution, the revolution was able to govern them

— បំផុសចលនាបង្កបង្កើនផល ពិសេសស្រូវ និងស្បៀង

ដោយមានការទាន់ពាត់តាំងនេះ ប្រជាជនត្រូវពឹងផ្អែកបដិវត្ត ហើយបដិវត្តគ្រប់គ្រងគេបាន ។

ដូច្នេះ ឆ្នាំ ១៩៧២ ជាផ្លូវបត់មួយ នៃការរៀបចំកម្លាំងប្រជាជន នៅក្នុងមូលដ្ឋានរបស់យើង ។ ព្រោះយ៉ាងនេះ តើយើងប្រមូលកម្លាំងបាន ។ តែបើយើងគ្រាន់តែឃោសនាអប់រំ ហើយមិនដណ្តើមយកសេដ្ឋកិច្ចពីសក្តិភូមិ នាយទុន គឺយើងមិនមានកម្លាំង ។ ដល់យើងមានកម្លាំងមូលដ្ឋានហើយ យើងប្រមូលកម្លាំងស្រទាប់ឯទៀតបាន ។ ដល់យើងមានកម្លាំងប្រជាជនហើយ គឺដឹកនាំចលនាវាយសក្តិភូមិ-ម្ចាស់ដី នាយទុន ធ្វើឲ្យពួកវាបាត់ម្ចាស់ការ ។ ជានៈ ប្រជាជនឡើង ចលនាបដិវត្តឡើង អានុភាពបដិវត្តក៏ឡើង ។ សម្ពន្ធភាពកម្មករ-កសិករ រឹងប៉ឹង ធំធេងលាយ ក្រោមការដឹកនាំរបស់បក្ស ។

!! ?Z and gather forces

propaganda is insufficient to make people attack designated enemies

ពិសោធន៍នេះ បានបង្ហាញឲ្យឃើញថា ៖

1. ត្រូវផ្អែកលើចលនាជាក់ស្តែង ដើម្បីពិនិត្យកម្លាំង ។ យកចលនាជាក់ស្តែងរបស់មហាជន ពិនិត្យមើល តើយើងមានកម្លាំងប៉ុន្មាន យ៉ាងណា ហើយត្រូវរៀបចំបង្កើន

កម្លាំងយ៉ាងណា មិនរៀបចំយ៉ាងម៉េច ? ត្រូវមានវិធានការណ៍ចំពោះវណ្ណៈសក្តិភូមិ នាយទុន កុំទៅប្រកួតប្រណាំងជាមួយវាដោយសន្តិវិធីដាច់ខាត ។

no peaceful methods for use against class enemies

2. ដើម្បីប្រមូលកម្លាំងប្រជាជនឲ្យខ្លាំងក្លាមិនដាច់លាប់ ត្រូវមានចលនា ត្រូវបំផុសចលនាឲ្យជាប់ តាំងពីចលនាធ្វើស្រែ លើកទំនប់ បង្កបង្កើនផល ត្បាញរវៃ ។ល។ តាមពាក្យស្លោក បំផុសជាប់ ដុតជាប់ ក្តៅជាប់ ។ ក្រោយរំដោះប្រទេសបានតាំងស្រេច យើងបំផុសចលនាបង្កបង្កើនផល ទូទាំងប្រទេស ។ ក្នុងចលនានេះ យើងកសាងទស្សនៈថ្មី គោលជំហរថ្មី បច្ចេកទេសថ្មី ឲ្យប្រជាជនយើង

production movement transforms people

builders state power and dictatorship

## ៣. ការកសាង ពង្រឹងនិងពង្រីក រដ្ឋអំណាច បដិវត្តរបស់បក្ស និងផ្តាច់ការបដិវត្ត របស់បក្ស

— ចំពោះបញ្ហានេះ ក៏មានការប្រឆាំង ។ រវាងមាគ៌ាឯករាជ្យ-ម្ចាស់ការ ខ្លួនទុកដាក់ខ្លួន និងមាគ៌ាឈ្លានពានមកលើកម្ពុជាយើង ។

struggle between lines of independence-mastery-self reliance and aggression



បន្ទាប់ពីលើកភ្លឺ ជីកប្រឡាយថ្មី កាត់ខ្វែងផ្ទៃស្រែជាក្រឡាលើត្រង់ហើយ សមាជិកសហករណ៍យើង វាយសំរុកជីកគាស់រំលើងដំបូក និងគល់ឈើនៅក្នុងស្រែទាំងអស់ ដើម្បីសំអាត និងពង្រាបផ្ទៃស្រែឲ្យបានស្មើ ងាយស្រួលក្នុងការចែកចាយទឹក ។

cooperative water works

— ការប្រយុទ្ធជាមួយពួកសក្តិភូមិ - ម្ចាស់ដី អ្នកស្រែមាន និងនាយទុន ដោយពួកនេះ ក៏ចង់ក្តាប់រដ្ឋអំណាច

— ការប្រយុទ្ធ រវាងមាគ៌ាពិតត្រង់រដ្ឋអំណាចបដិវត្តរបស់បក្ស និងពួកឱកាសនិយមផ្សេងៗ ដែលចូលមកកាន់កាប់រដ្ឋអំណាច តាមកាលៈទេសៈពេលនោះ

— ការតស៊ូរវាងបក្សបដិវត្តយើង ហើយនិងការចង់បានរដ្ឋអំណាចឡើងវិញ របស់សមាសភាពមិនល្អក្នុងស្រទាប់លើ ដែលនៅក្នុងជួររណសិរ្ស ។

ទិសដៅបដិវត្តយើង គឺកំទេចរដ្ឋអំណាចចាស់ កសាងរដ្ឋអំណាចបដិវត្តថ្មី ។ យើងបានដណ្តើមជាបន្តបន្ទាប់មក ។ យើងរីកចំពង្រីកពង្រីករដ្ឋអំណាចនេះ តែទន្ទឹមនឹងនេះ ពួកខ្មាំងសត្រូវក៏ចង់ដណ្តើម ដោយម៉្យាង វាចាត់តាំងផ្ទាល់ ៗ ឯវិធីប្រយោល គឺបញ្ចូលមនុស្សវា ដែលវាកាន់ទងបាន ចូលរដ្ឋអំណាចភូមិ-ឃុំ តាមវិធីផ្សេងៗ ។ វិធីប្រយោលមួយទៀត គឺតាមរយៈកម្មាភិបាលយើង ដែលវាកាន់ទងបានជាកម្មាភិបាលមូលដ្ឋាន ។ យោធា សេដ្ឋកិច្ចរហូតដល់ដណ្តើមរដ្ឋអំណាចនៅក្នុងបក្ស ដោយរៀបចំកម្លាំងដឹក

with feudalists et

with opportunists

against bad elements in the Front

smash the old, construct the new

enemy infiltration of villages, sub-dists and even of party itself

with help of opportunists; constant and bloody struggle in which party must maintain initiative

ទាំង ជាបន្តបន្ទាប់ តាមរយៈដៃជើងវា និងពួកសមាសភាពទុកាស-
និយម ។ ការប្រយុទ្ធនេះ មានជាបន្តបន្ទាប់ ហើយមានការបង្ហូរ
ឈាម ។ តែផែនការនេះ ត្រូវវាយឲ្យខ្ចាត់ខ្ចាយ ជាបន្តបន្ទាប់
ដោយមកពីយើង មានទស្សនៈត្រឹមត្រូវ ចំពោះជាតុពិត និងគោល
បំណងល្បាចពាល របស់ខ្មាំងសត្រូវ ។ ដូច្នេះ យើងបំពាក់
គោលជំហរ ទស្សនៈ ឲ្យបក្ស ប្រជាជន និងកងទ័ព បាន
ខ្ជាប់ការ ។

infiltration in 72-73

ការដណ្តើមរដ្ឋអំណាច របស់យើង និងវណ្ណៈជិះជាន់
ផ្សេងៗ ក្នុងតំបន់រំដោះយើង គឺតាមមូលដ្ឋានមួយៗ ពួកវារៀបចំ
កម្លាំងវា ឲ្យចូលក្នុងអង្គការយើង មាននៅក្នុងឆ្នាំ ១៩៧២-
១៩៧៣ ។ វណ្ណៈនេះ ចង់មានសិទ្ធិអំណាច ក្នុងរបបថ្មី ។ តែ
ពួកនេះ ដណ្តើមមិនបាន ដោយបក្សបានបំពាក់បំប៉ន និងពង្រឹង
គោលជំហរវណ្ណៈអធន ជាប់ជានិច្ច ។

lots of opportunists come in since 1970, but have been purged

ពួកទុកាសនិយម តាំងពីឆ្នាំ ១៩៧០មក ក៏ចូលច្រើន
ជាថ្នាលឲ្យខ្មាំង ធ្វើសកម្មភាពចូលជ្រៀតជ្រែក ប្រឆាំងបដិវត្ត
បាន ។ ពួកនេះ យើងសំអាតសំអាំងជាបន្តបន្ទាប់ ។ ពួក
សមាសភាពមិនល្អ ក្នុងរណសិរ្សខាងលើ មានបំណងរក្សា
សិទ្ធិអំណាចចាស់របស់គេ តាមរយៈនេះ គេសង្ឃឹម ពង្រឹងនិង



ពង្រីករដ្ឋអំណាចគេ តាមរយៈរបបថ្មី បានមួយកំរិតទៀត ។
ចក្រពត្តិអាមេរិក បាកំង គាំសង្ឃឹម ដើម្បីបានទាក់ទងវិញ
ជាមួយពួកនេះ ។

new constitution is a form of struggle against bad elements

យើងដណ្តើមជ័យជំនះបាន មកពីយើងកំណត់ជាតុពិត
នៃរដ្ឋអំណាចបដិវត្តបានត្រឹមត្រូវ រហូតដល់ប្រកាសប្រើរដ្ឋធម្មនុញ្ញ
ថ្មីបដិវត្ត ។ យើងអនុវត្តផ្តាច់ការបដិវត្ត ជាបន្តបន្ទាប់ រដ្ឋអំណាច
ខាងនយោបាយ យោធា សេដ្ឋកិច្ច ។ល។ បក្សយើងក្តាប់
ទាំងអស់ ។ តទៅមុខទៀត យើងត្រូវយកចិត្តទុកដាក់ក្តាប់ ពង្រឹង
និងពង្រីករដ្ឋអំណាចបដិវត្ត របស់បក្សតទៅទៀត ឲ្យរដ្ឋអំណាច
នេះបរិសុទ្ធតទៅទៀត ។ ពិតមែនតែសក្តិភូមិ នាយទុន រលំរលាយ
ចក្រពត្តិអាមេរិកនិងបរិវារវា ត្រូវបរាជ័យ ខ្មាំងសត្រូវឯទៀត បែក
ខ្ចាត់ខ្ចាយ តែពួកវានៅតែធ្វើសកម្មភាព និងរកវិធីដណ្តើមរដ្ឋ-
អំណាច ពីយើងតទៅទៀត ។ វិធីរបស់វាគឺ ដោយបំបែកបំបាក់
លើកដាក់ បន្លំមាគ៌ា រហូតដល់ត្រៀមយុទ្ធភ្លើងតទៅទៀត
ពិសេសខាងសីលធម៌ ។

must further purify state power because defeated and scattered enemies still trying to seize state power and corrupt it morally

ការទប់ទល់សំខាន់របស់យើងគឺ ឯកភាពផ្ទៃក្នុងបក្ស
ផ្ទៃក្នុងប្រជាជន ផ្ទៃក្នុងកងទ័ពបដិវត្ត ទាំងខាងនយោបាយ សតិ-
អារម្មណ៍ និងចាត់តាំង ។ there is complete unity on need to purify

Army building and military line

## ៤. អំពីការកសាង ពង្រឹង និងពង្រីកកងទ័ពបដិវត្ត របស់បក្ស និងការអនុវត្តមាគ៌ាយោធា មាគ៌ាប្រយុទ្ធ របស់បក្ស

life & death struggle over military line

ចំពោះបញ្ហាកសាង កម្លាំងកងទ័ពបដិវត្តរបស់បក្ស របស់យើង គឺយើងឈរលើគោលជំហរ ឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ជាមូលដ្ឋាន ទាំងការរៀបចំកងទ័ព ការកសាងកម្មាភិបាល មាគ៌ាប្រើប្រាស់អាវុធ មាគ៌ាប្រយុទ្ធ ។ល។ តែគោលជំហរប្រឆាំងនឹងមាគ៌ានេះ ក៏មានចេញមក ពីខ្មាំងសត្រូវទៀត ៗ មានការប្រយុទ្ធគ្នាតែង មានសភាពស្លាប់-រស់ ឈ្នះចាញ់សង្គ្រាមតែម្តង ៗ

### 1. មាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស

relys on politics and people to compensate for temporary weakness

ដំបូង ខ្មាំងនៅខ្លាំងជាងយើង ខាងយោធា ៗ យើងខ្លាំងជាងវា ខាងនយោបាយ តែខ្សោយជាងវាជាបណ្តោះអាសន្ន ខាងយោធា ៗ យើងលើកមាគ៌ា គឺប្រជាជនទាំងមូលចូលរួមគ្រាស្រ័យ ធ្វើសង្គ្រាមប្រជាជន ទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ៗ វាយខ្មាំងទាំងយោធា នយោបាយ សេដ្ឋកិច្ច គ្រប់ផ្នែក ៗ

យើងបំផុសប្រជាជនបាន ប្រជាជនធ្វើទាំងអស់ តាំង



ពីដឹកជញ្ជូន បង្កបង្កើនផល ចូលទ័ព ។ល។

វាយខាងនយោបាយ មានទិដ្ឋភាពច្រើន ៗ យើងវាយវាបានជាប់ ព្រោះវាក្បត់ជាតិ ពុករលួយ ហ្វាស៊ីស ៗ យើងសង្កត់វាជាប់ ៗ

5- applies to Lon Nol (not to Vietnamese?)

ចំណុចនយោបាយមួយទៀត នៃសង្គ្រាមប្រជាជន គឺពង្រីកប្រជាជនពីខ្មាំង មិនឲ្យខ្មាំងយកប្រជាជនបាន ៗ វាយសមរភូមិមួយ ៗ យើងដកយកប្រជាជនអស់ ៗ បញ្ហានេះ ជាកម្លាំងមួយខ្លាំង ដោយវាយបំទ្រឹស្តីនិចសុន ដែលយកខ្មែរសម្លាប់ខ្មែរ ៗ យើងវាយខាងសេដ្ឋកិច្ច ដោយបំផ្លាញសេដ្ឋកិច្ចខ្មាំង ព្រោះសេដ្ឋកិច្ចគេច្រើនដាច់ខាតនៅក្នុងតំបន់រំដោះយើង ៗ

drying the people up from the enemy

យើងបំផុសប្រជាជននៅក្រុង តស៊ូច្រើនរូបភាព វាយចំក្បាលម៉ាស៊ីនគ្រប់គ្រងកណ្តាល របស់ខ្មាំង ៗ

whip up an urban struggle

### 2. បញ្ហាកសាងកងទ័ព បំពាក់អាវុធ និងមាគ៌ាប្រយុទ្ធ

ជាតុវណ្ណៈរបស់កងទ័ព គឺវណ្ណៈអធន ក្រោមការដឹកនាំរបស់បក្សដាច់ខាត ៗ សមាសភាព ភាគច្រើនដាច់ខាត គឺកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម ដែលបានលត់ដំខ្លួន ចលនាសង្គ្រាមផ្ទាល់ ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ៗ

proletarian army = poor peasant army under Party leadership

*guerilla vs full-scale (regular) warfare*

យើងបំពាក់អាវុធ តាមគោលជំហរឯករាជ-ម្ចាស់ការ តាមលទ្ធភាព និងវាយយកបានពីខ្មាំង ។

មាគ៌ាប្រយុទ្ធរបស់យើង គឺវាយឈ្លប និងសំរុករបប ។ ពេលខ្លះ យកឈ្លបជាមូលដ្ឋាន ពេលខ្លះយកសំរុករបបជាសំខាន់ ។ យើងវាយផ្លូវគមនាគមន៍ វាយខាងក្នុងបរិវេណខ្មាំង វាយខាងក្រៅបរិវេណខ្មាំង វាយតូច វាយកាត់ ។ល។ ពេលយើងវាយផ្តាច់ព្រៀត គឺ យើងវាយផ្តុំព័ទ្ធជុំវិញក្តាំពេញ វាយតាមខេត្ត វាយទន្ទ្រានភូមិ ដោយយកភូមិជាគន្លឹះ ។ *[NB: no clarification of issues here (i.e. what was conflict about)*

*Economy & Finances*

## ៥. ការកសាងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ របស់បក្ស

ក្នុងរយៈកាលអនុវត្តសង្គ្រាមប្រជាជន យើងរៀបចំកសាង ពង្រឹងនិងពង្រីកសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ព្រោះវាមានតួនាទីសំខាន់ណាស់ ក្នុងសង្គ្រាមរំដោះជាតិ រំដោះប្រជាជន ។ បើសេដ្ឋកិច្ច-ហិរញ្ញវត្ថុដើរមិនស្រួល គឺបរាជ័យ ។

មាគ៌ាសេដ្ឋកិច្ច-ហិរញ្ញវត្ថុរបស់យើងគឺ ៖

ចំណុចពិសេសទី១ គឺមាគ៌ាបង្កបង្កើនផល ផលិតកម្មស្រូវ និងស្បៀងផ្សេង ៗ ។ ផលិតកម្មនេះ ជាស្នូលនៅសមរភូមិក្រោយ ។ កម្លាំងសមរភូមិខាងក្រោយទាំងអស់ បំរើផលិតកម្ម ។



មាគ៌ានេះ បានបង្ហុសលទ្ធផលល្អ ពិសេស តាំងពីឆ្នាំ១៩៧២ ។ មាគ៌ានេះ បំរើបាន គោលជំហរឯករាជ-ម្ចាស់ការ ខ្លួនទុកខ្លួន កំរិតខ្ពស់បំផុត ។

ចំណុចពិសេសទី២ គឺរដ្ឋក្តាប់ផ្នែកពាណិជ្ជកម្មសំខាន់ទាំងអស់ ។ ធ្វើឲ្យសភាពការណ៍ ត្រួតត្រាប់ចាក់ មានផលប្រយោជន៍ ដល់សង្គ្រាមបដិវត្ត គាត់រំដេីងឈ្មួញក្នុងស្រុក ឈ្មួញបរទេស បំរើចក្រពត្តិ ហើយធ្វើឲ្យពួកវាំណបយើងវិញ ។ វិធានការខ្ទាំងក្លានេះ បំរើសំណូមពរសង្គ្រាមបដិវត្តបាន បំរើផលិតកម្មបាន បំរើជីវភាពប្រចាំថ្ងៃរបស់ប្រជាជនបាន ។

ចំណុចពិសេសទី៣ គឺការរៀបចំចាត់តាំងសហករណ៍ នៅតំបន់រំដោះទី១ ទី២ កំរិតទាប-កំរិតខ្ពស់ ដែលជាវិធានការវាយការទាត់ចង់ផលិតកម្មចាស់ កសាងការទាត់ចង់ផលិតកម្មថ្មី ។ សហករណ៍ ជាបន្ទាយឲ្យកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម ។ សហករណ៍នេះ វាយចំណុចក្រពត្តិ សក្តិភូមិ-ម្ចាស់ដី និងនាយទុន ។ *co-ops as basis for democracy*

ចំណុចពិសេសទី៤ គឺការមិនចាយលុយ ។ វិធានការនេះ យើងចាប់ផ្តើមពីឆ្នាំ ១៩៧៣ ។ មិនចាយលុយ មានន័យ *since '73: no money*

00809857

democratic in its attack on private property and its ideology



តាំងពីបដិវត្តប្រជាជាតិ និងប្រជាធិបតេយ្យ ហើយទប់ទល់ខ្លាំង បន្ថយកម្លាំងខ្លាំង ខាងហិរញ្ញវត្ថុបាន ។ ន័យខាងប្រជាធិបតេយ្យ គឺជាមធ្យោបាយមួយ កំចាត់កម្មសិទ្ធិឯកជន ជាសំភារៈ ជាគោល-ជំហរ សតិអារម្មណ៍ ។ ជាកម្លាំងធំណាស់ ក្នុងការធ្វើបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ។ បើគ្មានវិធានការទាំងនេះ យើងគ្មានកម្លាំងខាងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ។

crucial to rpu's economic strength

យើងធ្វើបាន មកពីយើងមានកម្លាំងគ្រប់គ្រាន់ គឺមានកងទ័ពខ្លាំងក្លា មានរដ្ឋអំណាចដិតដូចទាំងប្រទេស យើងប្រមូលកម្លាំងប្រជាជន បានកាន់តែច្រើន ហើយក្រោមការដឹកនាំ របស់បក្សដាច់ខាត ។

possible to the extent have armed strength and control administration

យើងដំណើរការទៅបានយ៉ាងនេះ ដោយបក្សតាមដានចលនាជាប់ ហើយចលនានេះ វាបង្ហាញយើងថា តើត្រូវធ្វើអ្វី មិនត្រូវធ្វើអ្វី ?

NB: no mention of contradiction over this issue

## ៦. អំពីការកសាងវប្បធម៌ - សង្គមកិច្ច របស់បក្ស ដើម្បីបំរើសង្គ្រាមប្រជាជន

វប្បធម៌-សង្គមកិច្ច ក៏ជាកម្លាំងមួយនៃរដ្ឋអំណាចចាស់ៗ កម្លាំងនេះ បានពង្រឹងនិងពង្រីក ដុះស្លូកបំពាន់ឆ្នាំ មានលក្ខណៈ



សក្តិភូមិ នាយទុនប្រតិកិរិយា ចក្រពត្តិ ដូច្នេះ ការធ្វើបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ក៏វាយរំលំវប្បធម៌-សង្គមកិច្ចចាស់នេះដែរៗ ពិសេស ក្រោយមហាសន្និបាតបក្សលើកទីIIIឆ្នាំ១៩៧១ យើងបន្តវាយបោសសំអាតក្លាម អស់ជាមូលដ្ឋាន ហើយបោសសំអាតវាជាបន្តបន្ទាប់ ។

ការតស៊ូនេះ ក៏ជ្រាលជ្រៅណាស់ដែរ ។

មូលហេតុ ដែលធ្វើឲ្យរំលំរលាយវប្បធម៌ - សង្គមកិច្ចចាស់ មានកត្តា២ :

១. កត្តាបក្សដឹកនាំ ដែលបែងចែកវប្បធម៌បដិវត្ត និងមិនបដិវត្តច្បាស់លាស់ ហើយមានគោលជំហរប្រយុទ្ធ ច្បាស់លាស់ ដាច់ខាត ។

២. កត្តាទី ២ គឺយើងមានកម្លាំង ដូច្នេះ អនុវត្តបានរហ័ស ។ បើមានតែកម្លាំងសំភារៈ តែបើគ្មានកម្លាំងគោលជំហរ ក៏អនុវត្តមិនបាន ។

ដូច្នេះ យើងវាយរំលំទាំងរបបយោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌-សង្គមកិច្ច របស់របបសក្តិភូមិ នាយទុន អស់ជាឫសគល់ ។ តែអានុភាពចាស់ នៃវប្បធម៌-សង្គមកិច្ចចាស់ វានៅសេសសល់ដែរ ដែលយើងបន្តការតស៊ូកំចាត់ទៅទៀត ។

00809858

Stance = speed



អំពីការកសាងវប្បធម៌ - សង្គមកិច្ចថ្មី យើងមិនផ្អែកលើបច្ចេកទេសទេ ។ យើងឈរលើគោលជំហរបដិវត្ត ដើម្បីកសាងបច្ចេកទេស ។ ត្បិតអ្វីៗមិនបដិវត្ត យើងមិនធ្វើ ។

បើយើងមិនឃ្លាតពីគោលជំហរបដិវត្ត នៃវណ្ណៈអធននេះ យើងមុខជាលឿន ព្រោះយើងដើរផ្លូវកាត់ត្រង់ មិនក្រឡិកក្រឡក់

## ៧. ការកសាង ពង្រឹងពង្រីកមូលដ្ឋានបង្អែក បំ រើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន

reliable base areas vs new LZs

ក្រោយរដ្ឋប្រហារ យើងរំដោះបានទឹកដី ៧០-៧៥ ភាគរយភ្លាម ។ មូលដ្ឋានរំដោះ ធំទូលាយ ចែកជាមូលដ្ឋានបង្អែកចាស់ និងរំដោះថ្មី ។ cf, 1975

ហៅជាមូលដ្ឋានបង្អែក គឺប្រជាជនខ្លាំង កងទ័ពខ្លាំង សេដ្ឋកិច្ចខ្លាំង បន្ទាប់មក គឺកត្តាភូមិសាស្ត្រ ។ ពេលយើងរំដោះធំទូលាយ បើនៅតែរក្សាមូលដ្ឋានបង្អែកចាស់ យើងបំរើការកិច្ចបដិវត្តមិនបាន ។ ដូច្នេះ បក្សសំរេចយកតំបន់រំដោះទាំងមូលទូទាំងប្រទេស ធ្វើជាមូលដ្ឋានបង្អែក គ្រាន់តែមានចំណុចខ្ពស់-ទាប រឹង-ខ្សោយ តាមលក្ខណៈសម្បត្តិរបស់វា ។ ឈរលើទស្សនៈនេះ គ្រប់ទីកន្លែង ត្រូវមានកងទ័ពរឹងប៉ឹង ទាំងពីរប្រភេទ ។ រដ្ឋអំណាច

natural uniformity

strong everywhere: militarily & political administration



E169/4/1-1-2

រឹងប៉ឹង ។ ត្រូវក្តាប់ប្រជាជន ឲ្យបានដាច់ខាត ។ ទន្ទឹមនេះ កសាងសេដ្ឋកិច្ចឲ្យខ្លាំង ។ បក្សដឹកនាំ ត្រូវខ្លាំង ។ បើកន្លែងណាៗ មានលក្ខណៈសម្បត្តិយ៉ាងនេះ វាជាមូលដ្ឋានបង្អែក ។ ធ្វើយ៉ាងនេះ សូម្បីតែនៅជុំវិញភ្នំពេញ ក៏ជាមូលដ្ឋានបង្អែកបានដែរ ។ យើងត្រូវកសាងមូលដ្ឋានបង្អែក ទូទាំងប្រទេស កន្លែងណា ក៏ជាមូលដ្ឋានបង្អែក ។

## ៨. កិច្ចការបរទេស របស់បក្ស

Foreign affairs

ជាផ្នែកមួយ នៃការងារបដិវត្តរបស់យើង ក្នុងការរំដោះជាតិ រំដោះប្រជាជន ។ វាមិនមានតួនាទីជាកត្តាកំណត់ទេ តែវាទាក់ទងដល់យុទ្ធសាស្ត្រ-យុទ្ធវិធីសង្គ្រាមប្រជាជន របស់យើង ។

not decisive factor

តើយើងដំណើរការ យ៉ាងម៉េច ?

1. ការងារបរទេស របស់បក្ស ផ្អែកសំខាន់បំផុត លើកត្តាអត្តនោមតិ លើចលនា លើកម្លាំងបដិវត្តរបស់ខ្លួន លើជ័យជំនះក្នុងប្រទេស ។ តទៅថ្ងៃមុខទៀត យើងនៅតែត្រូវឈរ លើកត្តាអត្តនោមតិតទៅទៀត លើជំហរឯករាជ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ។

based on subjective factors strength & victory

2. លើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ ប្រុងប្រយ័ត្នបដិវត្ត លើគ្រប់ផ្នែក ទាំងខាងយោបាយ

all-round vigilance

00809859



សតិអារម្មណ៍ និងចាត់តាំង ។ បញ្ហានេះ ក៏មានគួនាទីជាយុទ្ធសាស្ត្រ សំខាន់ណាស់ដែរ ។

## ៩. បញ្ហាទប់ទល់ និងកំចាត់សកម្មភាពចារកម្ម ដែលប៉ងបំផ្លិចបំផ្លាញបដិវត្តយើង

espionage war by US & "other sources"

សង្គ្រាមចារកម្ម ពីខាងចក្រពត្តិអាមេរិក-បរិវារ និងពីប្រភពផ្សេងៗ គឺសំដៅស៊ីរូងយ៉ាងជ្រាលជ្រៅ ដោយមានបំណងវាយកំទេចគណៈបក្ស និងបដិវត្តយើង បំណងគ្រប់គ្រងយើង ។ សកម្មភាពវា គឺវាយតាំងយុទ្ធវិធី និងយុទ្ធសាស្ត្រ ។ ចំពោះមុខគឺកុំឲ្យយើងឈ្នះសង្គ្រាម ។ តែពេលបដិវត្តឈ្នះ វាបន្តសកម្មភាពទៅទៀត ធ្វើឲ្យបដិវត្តប្រែពណ៌សំបុរ តែយើងបានកំចាត់វាឲ្យខ្ចាត់ខ្ចាយជាបន្តបន្ទាប់ ។

eliminate efforts to change the revolution's colour

ពិសោធន៍ បានបង្ហាញឲ្យឃើញថា ៖

១. ត្រូវមានគោលជំហរ វិភាគខ្មាំង-សត្រូវ យុទ្ធសាស្ត្រ-យុទ្ធវិធី ឲ្យច្បាស់លាស់ ហើយមានវិធានការណ៍ច្បាស់លាស់ ប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់

២. មាន ប្រជាជន-មហាជន ដែលចំពាក់ដោយគោលជំហរ ប្រុងប្រយ័ត្នបដិវត្តខ្ពស់ ។ កំចាត់